Japan, your neighbor

# ញញឹមខ្មែរ
# NyoNyum Khmer

26 ឥតគិតថ្លៃ!
មីនា-មេសា ២០១៨

How to visit JAPAN
ព័ត៌មានសម្រាប់ធ្វើដំណើរទៅប្រទេសជប៉ុន



## តើអ្នកទាំងអស់គ្នាចង់ឃើញ ផ្កា SAKURA ឬ?

ប្រការដែលត្រូវនិយមនៅប្រទេសជប៉ុន
## Rental boyfriend

ប្រពៃណី និងវប្បធម៌
## Cambodia Festival 2018



# Contents

# 26

Mar-Apr 2018


០៣ **Special**

**តើអ្នកទាំងអស់គ្នាចង់ឃើញផ្កា SAKURA ឬ?**

**Series**

០៨ Tradition & Culture ប្រពៃណីនិងវប្បធម៌
**ប្រពៃណីពាក់ព័ន្ធនឹងផ្កា SAKURA**

០៩ Japan View គយគន់ទេសភាពប្រទេសជប៉ុន
**រូបផុតពីគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរ**
Inner Bay, Kesennuma Port, Miyagi

១០ Khmer vs Japanese ខ្មែរ vs ជប៉ុន
**"តើអ្វីទៅជាផ្កាដែលអ្នកចូលចិត្ត ?"**

១២ Trend in Japan ចំនុចដែលគួរចាប់អារម្មណ៍នៅប្រទេសជប៉ុន
**សេវាកម្មជួលមិត្តប្រុស**

១៣ Business Talk បទសម្ភាសន៍ធុរៈជន
**JCGroup**
អគ្គនាយកប្រតិបត្តិ ( President CEO ) លោក Ko Honam

១៤ EVENT INFORMATION & REPORT
ព័ត៌មានព្រឹត្តិការណ៍ និងរបាយការណ៍
**“មហោស្រព តីហ្សូណា ជប៉ុន-កម្ពុជា ២០១៨”**
**“CAMBODIA FESTIVAL 2018”**

១៦ JAPAN in CAMBODIA
ប្រទេសជប៉ុនដែលទទួលបទពិសោធន៍នៅកម្ពុជា
**ស្ថាប័នសុខាភិបាលមកពីជប៉ុននៅភ្នំពេញ**
Ken Clinic / Iwata Dental Clinic

១៩ Japanese Recipe សូមសាកល្បង
**Dorayaki (នំជប៉ុន)**

២០ Report from Japan ការរាយការណ៍ពីប្រទេសជប៉ុន
**ទីបំផុត ខ្ញុំបានមកដល់ប្រទេសជប៉ុន!**
ផាន់ ផល្លី

២១ Bong Yuki Essay ជ្រុងមួយរបស់បងយូគី
**ប្រការភ្ញាក់ផ្អើលស្តីពីភាពខុសគ្នា**
**នៃទម្លាប់ជីវភាពរវាងជប៉ុននិងកម្ពុជា**

២២ Fortune Telling ហោរាសាស្ត្រប្រចាំខែ
**ហោរាសាស្ត្រប្រចាំខែមីនា និងមេសា**

២៤ How to vist JAPAN
**ទៅទស្សនានៅជប៉ុន តើយើងគួរស្វែងយល់ចំនុចណាខ្លះ ?**
ព័ត៌មានមូនដ្ឋានរបស់ប្រទេសជប៉ុន /
អាកាសធាតុនិងរដូវ / រៀបចំដើម្បីទៅដើរលេង /
ការដឹកជញ្ជូននៅប្រទេសជប៉ុន


## Editor's Note

និទាឃរដូវជិតមកដល់ហើយ! ក្រោយបានចូលខែមីនាហើយ រដូវរងារដែលត្រជាក់ខ្លាំងត្រូវឈានដល់ទីបញ្ចប់ ហើយអាកាសធាតុនឹងចាប់ផ្តើមកក់ក្តៅបន្តិចម្តងៗ ហើយចុងខែមីនានឹងមានផ្កា SAKURA ចាប់ផ្តើមរីក។ នៅប្រទេសជប៉ុននិទាឃរដូវគឺជាពេលវេលាមួយសម្រាប់ចាប់ផ្តើមអ្វីៗជាច្រើន។ គេនឹងបញ្ចប់ការសិក្សានៅត្រឹមចុងខែមីនា ហើយចាប់ពីខែមេសាទៅវិសមកាលថ្មីនឹងចាប់ផ្តើម។ អ្នកខ្លះឡើងថ្នាក់អ្នកខ្លះចូលធ្វើការ ខ្លះចាប់ផ្តើមការងារឬជីវភាពនៅតំបន់ថ្មីដោយការចាត់តាំងប្តូរកន្លែងធ្វើការក្នុងក្រុមហ៊ុនជាដើម..។

ក្នុងនិទាឃរដូវថ្មីនេះ ទស្សនាវដ្តី “ញញឹមខ្មែរ” ដែលត្រូវចាប់កំណើតឡើងនៅឆ្នាំ២០១៤ក៏ត្រូវប្តូរថ្មីយ៉ាងច្រើន! ទាំងខ្លឹមសារទាំងរចនាបថឌីហ្សាញក៏ត្រូវផ្លាស់ប្តូរថ្មីដែរ។ ជាពិសេសឌីហ្សាញត្រូវផ្តោតលើភាពងាយស្រួលអាន ហើយខ្លឹមសារវិញគឺបានខិតខំប្រមូលប្រធានបទថ្មីៗជាច្រើនដើម្បីធ្វើយ៉ាងណានឹងក្លាយទៅជាទស្សនាវដ្តីមួយដែលជនជាតិកម្ពុជាមានអារម្មណ៍ស្និទ្ធស្នាលជាមួយជប៉ុនបាន។ “Trend in Japan” ដែលធ្វើការណែនាំពីសេវាកម្មឬវប្បធម៌ទាន់សម័យក្នុងសង្គមថ្មីៗនៃជប៉ុន។ “Tradition & Culture” ដែលណែនាំពីវប្បធម៌ឬទំនៀមទំលាប់លក្ខណៈប្រពៃណីជប៉ុន។ “JAPAN in CAMBODIA” ដែលណែនាំពីហាងឬស្ថាប័នជប៉ុននៅក្នុងប្រទេសកម្ពុជា។ ហើយចុងក្រោយនៃសៀវភៅនេះ មាន “How to visit JAPAN” ដែលប្រមូលផ្តុំនូវព័ត៌មានដែលមានប្រយោជន៍ក្នុងការធ្វើដំណើរទៅប្រទេសជប៉ុនដូចជាព័ត៌មានមូលដ្ឋានឬវិធីដាក់ពាក្យសុំទិដ្ឋាការជាដើម។ សូមអញ្ជើញប្រើប្រាស់សម្រាប់ប្រយោជន៍របស់អស់លោកអ្នក។

ពាក្យស្លោកនៃទស្សនាវដ្តី“ញញឹមខ្មែរ”ដែលបានផ្លាស់ប្តូរថ្មីគឺ “Japan, your neighbor”។ យើងខ្ញុំសង្ឃឹមថា តាមរយៈទស្សនាវដ្តីនេះប្រិយមិត្តអ្នកអានទាំងអស់នឹងមានអារម្មណ៍កាន់តែស្និទ្ធស្នាលជាមួយជប៉ុនប្រដូចអ្នកជិតខាងជាក់ជាមិនខាន។


**នាយកនិពន្ធ**
**ហាស៊ីម៉ូតុ យ៉ូស៊ីកុ**
nyonyum@cisinc.co.jp


ញញឹមខ្មែរ
NyoNyum Khmer
nyonyum.net


© CJSinc. 2018
រក្សាសិទ្ធិគ្រប់បែបយ៉ាងរាល់ការថតចម្លងដោយគ្មានការអនុញ្ញាត នឹងត្រូវផ្តន្ទាទោសតាមច្បាប់



**ម្ចាស់ការបោះពុម្ពផ្សាយ**
យ៉ាម៉ាហ្សាគី យូគីអេ
**ក្រុមនិពន្ធ និងទីផ្សារ**
ហាស៊ីម៉ូតុ យ៉ូស៊ីកុ
មិយ៉ាកាវ៉ា អេរី
កាណូ ហ៊ីរ៉ូអាគី
តាគុមិ កាត់ស៊ូម៉ូតុ
អូន ចិន្តា
អ៊ីតូ យ៉ូកុ
ប៊ិន ស្រីគីម
**ផ្នែករៀបចំ និង រចនា**
យូកុ
អ៊ួន ចាន់រ៉ា
**រោងពុម្ព**
Digital Advertising

# SAKURA

## តើអ្នកទាំងអស់គ្នាចង់ឃើញផ្កា SAKURA ឬទេ ?



សម្រាប់ជនបរទេសរួមទាំងប្រជាជនកម្ពុជា បើនិយាយអំពីប្រទេសជប៉ុន មនុស្សភាគច្រើននឹងស្រមៃដល់ផ្កា SAKURA មែនទេ ? ជាការពិតណាស់ផ្កា SAKURA គឺជាផ្កានិមិត្តរូបនៃប្រទេសជប៉ុន។

នៅខែមីនា អាកាសធាតុត្រជាក់ចុះខ្សោយបន្តិចម្តងៗ ប្រជាជនជប៉ុនកំពុងរង់ចាំការចេញផ្កានៃផ្កា SAKURA ទាំងចិត្តសប្បាយរីករាយ។ ពេលឃើញផ្កា SAKURA រីកមានអារម្មណ៍ថា “រដូវផ្ការីកបានមកដល់ហើយ”។ ដោយហេតុនេះហើយ ទើបទស្សនាវដ្តី "ញញឹមខ្មែរ" ជ្រើសរើសយកមកបង្ហាញ។ ផ្កា SAKURA នឹងរីកនាពេលឆាប់ៗនេះ។ វាចាប់ផ្តើមរីកនៅចុងខែមីនា ហើយទូទាំងប្រទេសជប៉ុននឹងពោរពេញដោយពណ៌ផ្កាឈូក។

# រដូវផ្កា SAKURA រីក (Sakura Zensen)

ប្រសិនបើអ្នកមានគំរោងទៅមើលផ្កា SAKURA នៅប្រទេសជប៉ុន សូមប្រុងប្រយ័ត្នលើពេលវេលា និងទីកន្លែងដែលត្រូវទៅ។ ចាប់ពីផ្កា SAKURA ចាប់ផ្ដើមរីករហូតដល់ជ្រុះគឺមានរយៈពេលពីរសប្ដាហ៍។ ហើយប្រទេសជប៉ុនគឺជាប្រទេសដែលលាតសន្ធឹងយ៉ាងវែងពីត្បូងទៅជើង។ ពេលវេលារីកនៃផ្កា SAKURA អាស្រ័យលើតំបន់។ មានករណីខុសគ្នាខ្លះដែរ ប៉ុន្តែជាទូទៅពេលរដូវផ្ការីកឈានមកដល់ផ្កា SAKURA រីកចាប់ពីតំបន់ក្ដៅនៅភាគខាងត្បូង ហើយតំបន់ត្រជាក់នៅភាគខាងជើងរីកតាមក្រោយ។ ដំណើរនៃការរីកនេះ គេហៅថា “Sakura Zensen ( ខ្សែព្រំប្រទល់រីក SAKURA )” ដែលប្រដូចនឹងពាក្យអាកាសធាតុនៅក្នុងប្រទេសជប៉ុន។ ផ្កា SAKURA បានចាប់ផ្ដើមរីកពីតំបន់ក្ដៅភាគខាងត្បូង ទៅតំបន់ត្រជាក់ភាគខាងជើង ហើយពីតំបន់ទំនាបទៅតំបន់ខ្ពង់រាប និងភ្នំដែលមានសីតុណ្ហភាពទាប។ ជារៀងរាល់ឆ្នាំអំឡុងខែកុម្ភៈ និងមីនាការទស្សន៍ទាយពីពេលវេលានៃការចេញផ្កានៃផ្កា SAKURA នឹងត្រូវប្រកាសនៅលើកញ្ចក់ទូរទស្សន៍។

បើទោះបីជាកន្លែងដែលអ្នកទៅទស្សនានោះផ្កា SAKURA ជ្រុះអស់ក៏ដោយ សូមកុំបោះបង់ចោល។ បើទៅភាគខាងជើងនេះរឺតំបន់ភ្នំអាចនឹងឃើញផ្កា SAKURA។

ផ្កា SAKURA ចាប់ផ្ដើមរីកចាប់ពីចុងខែមីនាទៅ។
( ※ប៉ុន្តែកោះអូគីណាវ៉ានៅភាគខាងត្បូងឆ្ងាយពីកោះមេគឺចាប់ផ្ដើមរីកនៅខែមីនា )។

នៅ Tohoku គឺចាប់រីកចាប់ពីខែមេសា។ នៅ Honshu ខេត្ត Aomori គឺរីកចាប់ពីចុងខែមេសា ចំណែក Hokkaido វិញចាប់រីកពីខែឧសភា។

### ▼ការទូស្សទាយន៍ផ្ការីកនៅឆ្នាំ2018

- Kyushu: ប្រហែល ថ្ងៃទី 20 ខែមីនា~
- Honshu - ភាគខាងលិចប្រទេសជប៉ុន និងភាគខាងកើតប្រទេសជប៉ុន: ប្រហែល ថ្ងៃទី 26 ខែមីនា~
- Honshu - ភាគខាងជើងប្រទេសជប៉ុន: ដើមខែមេសា~
- Hokkaido: នៅដើមខែឧសភា~

# ប្រភេទនៃ SAKURA

ទោះបីជានិយាយតែ SAKURA មួយតែវាមានប្រភេទផ្សេងៗជាច្រើន។ សូមលើកយកប្រភេទមួយចំនួនមកណែនាំ។





## Somei-yoshino

ជាពូជប្រភេទតំណាង ដែលត្រូវបានដាំយ៉ាងទូលំទូលាយនៅទូទាំងប្រទេស។ ទាំងជនជាតិជប៉ុន និងជនជាតិបរទេសពេលគេនិយាយពី SAKURA ហើយធ្វើការស្រមៃនោះគឺប្រហែលជាប្រភេទនេះហើយ។ “ពេលវេលាចេញផ្កានៃ SAKURA” ដែលបានរៀបរាប់ខាងលើនេះក៏សំដៅលើផ្កាប្រភេទនេះដែរ។ ដំបូងវាចេញផ្កាពណ៌ផ្កាឈូកនៅលើដើមដែលមានតែមែកឈើក្នុងរដូវរងារ ហើយរីកពាសពេញបន្ទាប់មកផ្កាវាចាប់ផ្ដើមធ្លាក់ហើយចេញស្លឹក។





## Yae-zakura

សំដៅលើប្រភេទផ្កា SAKURA ដែលពេលវារីកមានស្រទាប់ផ្កាជាច្រើនស្រទាប់។ វារីកយឺតជាងប្រភេទ Somei-yoshino ពី1~2សប្ដាហ៍ ហើយផ្ការបស់វាក៏រីកយូរទៀត ដូច្នេះគេអាចសប្បាយរីករាយក្នុងការមើលវារហូតដល់ចុងខែមេសា។

## Shidare-zakura

ជាផ្ការីកលើមែកវែងៗដែលធ្លាក់ជារំយោចុះមកក្រោម។ ចាប់ផ្ដើមចេញផ្កាចាប់ពីចុងខែមីនា~ខែមេសា ហើយផ្កាវាមានតែពណ៌ផ្កាឈូកស្លេកមួយពណ៌គត់។





## Yama-zakura

វាលូតលាស់តាមធម្មជាតិនៅលើភ្នំតាំងពីយូរណាស់មកហើយ ហើយក្នុងនោះ ក៏មានដើមដែលមានអាយុវែងជាងគេប្រហែលគឺ 1000ឆ្នាំ។ ចំណុចពិសេសវាគឺស្លឹកហើយផ្កាវាគឺលាស់តំណាលគ្នា។ បើទោះបីជានៅកន្លែងតែមួយជាមួយគ្នាក្ដីពេលវេលារីកនៃផ្កា SAKURA គឺផ្សេងៗគ្នាពីមួយដើមទៅមួយដើម ដូច្នេះគេអាចគយគន់ផ្កាវារយៈពេលយូរ។ “ផ្កា SAKURA នៅ Yoshino” ស្ថិតក្នុងខេត្ត Nara គឺមានភាពល្បីល្បាញណាស់។





# កន្លែងមើលផ្កា SAKURA




ប្រសិនបើអ្នកស្វែងរក "Cherry Blossom Viewing Spots" នៅលើអ៊ីនធើណេតអ្នកអាចស្វែងរកទីកន្លែងដ៏ល្អជាច្រើនទូទាំងប្រទេសជប៉ុន។ យើងចង់ណែនាំអ្នកនូវតំបន់មួយចំនួនដូចខាងក្រោម។

## ① ខេត្ត Fukushima Miharu Taki-zakura



វាធំហើយចាស់ណាស់ "Shidare-zakura" នៅទីក្រុង Miharu ខេត្ត Fukushima ។
វាត្រូវបានប៉ាន់ប្រមាណថាមានអាយុកាលជាង 1.000 ឆ្នាំ។ មែកឈើនេះរាលដាលសាខាប្រហែល 20 ម៉ែត្រ។

- រដូវ : នៅជុំវិញពាក់កណ្តាលខែ ឬចុងខែមេសា។
- ធ្វើដំណើរ : ដោយឡានក្រុងពីស្ថានីយ "Miharu" (JR Ban'etsu East line) *មានឡានក្រុងពិសេសនៅរដូវ SAKURA។

## ② ខេត្ត Niigata ឧទ្យានមួយ Takada



ឧទ្យាននេះគឺនៅ ទីក្រុង Echigo នៅ ខេត្ត Niigata។ ហើយវាមានភាពល្បីល្បាញសម្រាប់ភាពស្រស់ស្អាតក្នុងការបង្ហាញ វាជាកម្មវិធីពិសេសនៅក្នុងរដូវផ្កា SAKURA (នៅឆ្នាំ 2018 ចាប់ពីថ្ងៃទី 6 ខែមេសាដល់ថ្ងៃទី 22 ខែមេសា)។ មានដើមឈើ SAKURA ចំនួន 4.000 ដើម។

- រដូវ : នៅជុំវិញ ដើមខែមេសា-ចុងខែមេសា។
- ធ្វើដំណើរ : ប្រហែល 15 នាទីដើរពីស្ថានីយ Takakda (Echigo TOKImeki Railway)

## ③ រដ្ឋធានី Tokyo ទន្លេ Meguro



ទន្លេ Meguro គឺជាផ្នែកមួយនៃផ្កា SAKURA ល្អបំផុតនៅទីក្រុង Tokyo។ មានដើមឈើ SAKURA ច្រើនជាង 800 ដើមនៅតាមដងទន្លេប្រហែល 4 គីឡូម៉ែត្រ។ ក្នុងអំឡុងពេលពិធីបុណ្យសក្ការៈបូជា (នៅឆ្នាំ 2018 មិនប្រាកដថាកាលបរិច្ឆេទនៅឡើយទេ) អ្នកអាចរីករាយជាមួយនឹងការបង្ហាញដោយអាហារតាមចិញ្ចើមផ្លូវជាច្រើន។

- រដូវ : នៅជុំវិញ ចុងខែមីនា - ដើមខែមេសា។
- ធ្វើដំណើរ : ប្រហែល 7 នាទីដើរពីស្ថានីយ Komagome (JR Yamanote line / Tokyo Metro Nanboku line)

## ④ រដ្ឋធានី Tokyo Rikugi-en (Rikugi Garden)



វាគឺជាសួនដែលបានសាងសង់ជាង 300 ឆ្នាំមកហើយ។ ហើយឧទ្យាននេះមានភាពល្បីល្បាញសម្រាប់ "Shidare-zakura" ធំ។ មែកឈើនេះរាលដាលសាខាប្រហែល 20 ម៉ែត្រ។ មានកម្មវិធីពិសេសនៃការបង្ហាញមើលផ្កា SAKURA នៅរដូវ SAKURA (នៅឆ្នាំ 2018 ចាប់ពីថ្ងៃទី 21 ខែមីនាដល់ថ្ងៃទី 5 ខែមេសា)

- រដូវ : នៅជុំវិញ ចុងខែមីនា - ដើមខែមេសា។
- ធ្វើដំណើរ : ប្រហែល 7 នាទីដើរពីស្ថានីយ Komagome (JR Yamanote line / Tokyo Metro Nanboku line)

## 5 រដ្ឋធានី Kyoto Arashiyama



ទីក្រុង Arashiyama ជាតំបន់ទេសចរណ៍ដ៏ល្បីល្បាញមួយនៅជាយក្រុង Kyoto។ ដើមឈើ SAKURA ជាច្រើនអាចត្រូវបានរកឃើញនៅជុំវិញស្ពាន "Togetsukyo" នៅជើងភ្នំ Arashiyama។  មានកន្លែងដ៏ស្រស់ស្អាតមួយទៀតរបស់ SAKURA នៅក្នុងតំបន់នោះគឺវិហារ Daikakuji ដែលមានស្រះធំត្រូវបានព័ទ្ធជុំវិញដោយដើមឈើ cherry ។

- រដូវ : នៅជុំវិញ ពាក់កណ្តាលខែមីនា - ចុងខែមេសា
- ធ្វើដំណើរ : ប្រហែល 5 នាទីដើរពីស្ថានីយ Arashiyama ( Hankyu Arashiyama line )

## 6 រដ្ឋធានី Nara ភ្នំ Yoshino



វាត្រូវបានគេនិយាយថាជាដើមឈើដំបូងត្រូវបានគេដាំនៅតាមបណ្តោយចំណោតភ្នំជាង 1.300 ឆ្នាំមក ហើយសព្វថ្ងៃនេះភ្នំនេះត្រូវបានគ្របដណ្តប់ដោយដើមឈើ SAKURA ចំនួន 30.000នៃពូជខុសគ្នាជាច្រើន ជាពិសេសពូជ Yama-zakura ។

- រដូវ : នៅជុំវិញ ដើមខែមេសា - ចុងខែមេសា។
- ធ្វើដំណើរ : Ropeway ឬឡានក្រុងពីស្ថានីយ៍ Yoshino (Kintetsu Yoshino line)

អ្នកអាចរកកន្លែងជាច្រើនទៀតដើម្បីមើល SAKURA នៅទូទាំងប្រទេសជប៉ុននៅគេហទំព័រនេះ:https://www.japan-guide.com/e/e2011.html

# ប្រពៃណីពាក់ព័ន្ធនឹងផ្កា SAKURA

យើងនឹងណែនាំអំពីប្រពៃណី និងវប្បធម៌ពាក់ព័ន្ធនឹងផ្កា SAKURA របស់ជប៉ុន។

## ការមើលផ្កា

និយាយអំពីនិទាឃរដូវគឺតែងនឹកឃើញដល់ផ្កា SAKURA! ពាក្យថា"មើលផ្កា"គឺមិនបានសំដៅទៅការមើលផ្កាតែមួយមុខនោះទេ គឺដូចជាពិធីជប់លៀងមួយក្នុងពេលកំពុងមើលផ្កា។ យើងអាចសង្កេតឃើញបានថាចុងសប្តាហ៍នៃពេលដែលផ្កាបានរីកពាសពេញដើមនៅសួនច្បារឬវិថីដែលមានដើម SAKURA ដុះជាជួរៗនោះ មានមនុស្សជាច្រើនមកមើលផ្កា SAKURA ដោយដាក់កន្ទេលនៅក្រោមដើមឈើ។ ការស្រឡាញ់ចូលចិត្តផ្កាគឺជាវប្បធម៌ប្រពៃណីមួយរបស់ជនជាតិជប៉ុន។ កម្មវិធីមើលផ្កានេះត្រូវចាប់ផ្តើមក្នុងចំណោមអភិជននៅសម័យ Nara (710 - 794) ដែលដំបូងឡើយគេមិនមែនមើលផ្កា SAKURA ទេ គឺជាព្រឹត្តិការណ៍មួយសម្រាប់មើលផ្កា UME។ បន្ទាប់មកវាបានប្រែទៅជាផ្កា SAKURA នៅក្នុងសម័យ Heian (794 - 1185)។ វប្បធម៌មើលផ្កានេះត្រូវបានរីករាលដាលពីពួកអភិជនទៅពួក SAMURAI រហូតដល់ប្រជាជនសាមញ្ញ ហើយវាត្រូវបានបន្តមកដល់សម័យបច្ចុប្បន្ន។ នៅពេលរដូវត្រជាក់ត្រូវបានបញ្ចប់ហើយអាកាសធាតុវាក៏ចាប់ផ្តើមប្រែទៅជាក្តៅបន្តិចម្តងៗ។ ប្រជាជនជប៉ុនជាច្រើនបាននឹងកំពុងទន្ទឹងរង់ចាំការមកដល់នៃរដូវផ្ការីកដោយក្តីសប្បាយរីករាយ។ ចំពោះជនជាតិជប៉ុនការមើលផ្កាSAKURAគឺជាព្រឹត្តិការណ៍ដែលអារម្មណ៍សប្បាយរីករាយនានិទាឃរដូវ។ នៅក្នុងពិធីជប់លៀងមើលផ្កា យើងបាននាំយកប្រអប់អាហារ ភេសជ្ជៈ និងអ្វីៗផ្សេងទៀត។ យើងសប្បាយចិត្តណាស់ដោយសារតែយើងចំណាយលុយតិចជាងការទៅហាង។ ប្រជាជនកម្ពុជាអាចរីករាយនឹងដំណើរកំសាន្តនៅពេលអញ្ជើញទៅលេងប្រទេសជប៉ុនក្នុងកំឡុងពេលផ្កា SAKURA រីក។



### ចូររក្សាច្បាប់ និងវិន័យដើម្បីឱ្យសប្បាយ

សូមរីករាយមើលផ្កាដោយគោរពតាមច្បាប់ និងវិន័យដូចខាងក្រោម៖

- កុំធ្វើពិធីជប់លៀងនៅកន្លែងហាមឃាត់
(នៅលើឫសនៃផ្កា SAKURA និងស្មៅដែលត្រូវគ្រប់គ្រងត្រូវបានហាមឃាត់ដាក់កន្ទេល។)
- គោរពនិងរក្សាពេលវេលា (មានកន្លែងជាច្រើនត្រូវកំណត់ពេលវេលាសម្រាប់ជប់លៀង។)
- កុំបង្ករជម្លោះជាមួយនិងអ្នកដទៃពេលអ្នកស្រវឹង
- ធ្វើការវេចខ្ចប់និងយកទៅផ្ទះនូវសំរាមរបស់ខ្លួន

### ផ្កា SAKURA នាពេលយប់

មនុស្សជាច្រើនបានទៅមើលផ្កា SAKURA រីកនៅពេលយប់ក៏ដូចជាពេលថ្ងៃ។ ក្នុងរដូវកាលដែលរីក SAKURA ឆ្នាំសារពើពន្ធថ្មីរបស់ជប៉ុននឹងចាប់ផ្តើម។ មានករណីខ្លះបបួលសិស្សថ្មីឬអ្នកចូលធ្វើការថ្មីធ្វើការជប់លៀងមើលផ្កាសម្រាប់ពិធីស្វាគមន៍នៅពេលចេញពីសាលារៀនឬកន្លែងធ្វើការដែរ។ គេក៏រៀបចំតំឡើងភ្លើងដើម្បីឲ្យអ្នកមើលផ្កាអាចមើលឃើញបាននាពេលយប់។

## Ukiyoe និងផ្កា SAKURA







"Ukiyo-e" គឺជាកេរ្តិ៍ដំណែលឈើជប៉ុនមួយដែលមានប្រវត្តិសាស្ត្រប្រហែល 300ឆ្នាំ។ គេបង្កើតផ្ទាំងឈើដែលបានឆ្លាក់រូបជាច្រើនសន្លឹកហើយលាបពណ៌លើផ្ទាំងនីមួយៗនិងបោះពុម្ពនៅលើក្រដាសជប៉ុនមួយសន្លឹកដោយលាបពណ៌ជាន់គ្នាហើយនឹងក្លាយទៅជាគំនូរតែមួយ។ មានគំនូដែលមានភាពល្បីដូចជាគំនូរភ្នំ Fuji គំនូររបស់តួអង្គ Kabuki ឬស្ត្រីដែលស្លៀកពាក់ Kimono ជាដើម អ្នកអានមួយចំនួនធ្លាប់មើលតាមទូរទស្សន៍ឬ Internet ទេដឹង? SAKURA ផងដែរត្រូវបាននៅក្នុងការគូរដូចជា Ukiyo-e។ យើងអាចអះអាងបានថាវាជាផ្កាដែលត្រូវគូរឡើងនៅក្នុង Ukiyo-e ច្រើនជាងគេបំផុត។ នារីស្រស់ស្អាត និងដើមឈើ SAKURA, ផ្កា SAKURA នៅទីកន្លែងល្បីល្បាញ, ផ្កា SAKURA ក្នុងឆាកសម្តែង... ផ្កា SAKURA ត្រូវគេគូរនៅឈុតជាច្រើនបែបដែលបង្ហាញអោយដឹងថាតាំងពីដើមជនជាតិជប៉ុនពិតជាស្រឡាញ់ចូលចិត្តផ្កា SAKURA តែម្តង។



Created by modifying <Inner Bay, Kesennuma Port Miyagi>, © <TOMOYUKI HIRATA>,
Creative Commons Attribution 4.0 International License (CC BY 4.0)https://creativecommons.org/licenses/by/4.0/

## *គយគន់ទេសភាពប្រទេសជប៉ុន*

# រួចផុតពីគ្រោះមហន្តរាយដ៏ធ្ងន់ធ្ងរ




Inner Bay,
Kesennuma Port
Miyagi Prefecture

គ្រោះមហន្តរាយរញ្ជួយដីនៅតំបន់ឦសាននៃជប៉ុនកាលពីថ្ងៃទី១១ខែមីនា ឆ្នាំ២០១១។ តំបន់ឆ្នេរសមុទ្រប៉ាស៊ីហ្វិកនៅភាគឦសានត្រូវទទួលរងដោយសាររលកយក្ស Tsunami ដែលបណ្តាលអោយបាត់បង់អាយុជីវិតជាច្រើន។ នៅស្រុក Kesennuma ស្ថិតនៅភាគខាងជើងនៃខេត្ត Miyagi ដែលមានវិស័យនេសាទយ៉ាងសកម្មបានទទួលរងការខូចខាតយ៉ាងធ្ងន់ធ្ងរ និងប្រជាជនជាង១០០០នាក់ត្រូវទទួលមរណៈភាព។ ស្រុក Kesennuma នេះធ្លាប់មានឈ្មោះល្បីនៅទូទាំងប្រទេសជប៉ុនក្នុងនាមជាកំពង់ផែនេសាទដែលប្រមូលផលនៅតំបន់ឆ្នេរ Sanriku និងជាស្រុកមួយដែលមានសកម្មភាពនេសាទត្រី Tuna ដែលត្រូវចេញដំណើរទៅចាប់នៅឆ្ងាយៗពីឆ្នេរ។ នៅទីប្រជុំជនដែលជិតនឹងកំពង់ផែនោះត្រូវភ្លើងឆេះអស់៣ថ្ងៃបន្ទាប់ពីទទួលរងរលកយក្ស Tsunami ហើយបានក្លាយទៅជាវាលឆេះអស់រលីង។ ប្រជាជនដែលរស់នៅទីនោះបាត់បង់ក្តីសង្ឃឹមបន្តរស់ដោយសារបាត់បង់គ្រួសារក៏ដូចជាមិត្តភក្តិ ប៉ុន្តែពួកគេបានបួងសួងនូវការស្តារឡើងវិញសម្រាប់អនាគតនៃប្រជាជននៅមានជីវិតហើយបានចាប់ផ្តើមធ្វើសកម្មភាពនានា។

រហូតដល់ពេលនេះរយៈពេល៧ឆ្នាំបានកន្លងផុតទៅហើយ។ ពេលនេះជាដំណាក់កាលស្តារដែលត្រូវអភិវឌ្ឍន៍ជាបន្តទៅទៀត តែមានតំបន់ខ្លះពុំទាន់ត្រូវដាក់វិធានការស្តារនៅឡើយ និងមានបញ្ហាជាច្រើនត្រូវដោះស្រាយផងដែរ។ យ៉ាងណាមិញ ក្តីប្រាថ្នាដ៏ខ្លាំងក្លារបស់ប្រជាជនដែលមានដើមកំណើតនិងធ្លាប់បានរស់នៅទីនេះ បាននិងកំពុងសាងសង់ផ្ទះ បង្កើតទីផ្សារនិងអភិវឌ្ឍន៍ទីក្រុងថ្មីជាបន្តបន្ទាប់។ ដើម្បីឆ្ពោះទៅក្តីប្រាថ្នា និងក្តីសង្ឃឹមថ្មីដែលថានឹងបង្កើតទីប្រជុំជនដែលមានភាពសកម្ម និងមានលក្ខណៈទាក់ទាញដូចពីមុន ការតស៊ូរបស់ប្រជាជនទាំងឡាយនេះនឹងបន្តមិនដាច់ឡើយ។

# "តើអ្នកចូលចិត្តផ្កាប្រភេទអ្វី ?"

ដូចនឹងយើងបានលើកឡើងពីផ្កា "SAKURA" នៅក្នុងសៀវភៅនេះ យើងបានសាកសួរជនជាតិខ្មែរ៦នាក់ និងជប៉ុន៦នាក់ សរុបទាំងអស់១២នាក់។



ផ្កានេះ គឺជាផ្កាដែលរីកនៅពីមុខផ្ទះខ្ញុំ។ គ្រាប់ផ្លែរបស់វាដូចជាសណ្តែកហើយ ខ្ញុំញាំវាជាមួយមិត្តភក្តិជាញឹកញាប់ វាពិតជាឆ្ងាញ់ណាស់។ ខ្ញុំចូលចិត្តផ្កានេះ ពីព្រោះវារីកដុះដាលពេញមួយឆ្នាំ។



ចូលចិត្តផ្កា:
**ផ្កាក្ងោក**

ឈ្មោះ : ប៉ែម រិទ្ធីយ
ភេទ : ប្រុស
អាយុ : 21
ការងារ : សិស្ស



ខ្ញុំចូលចិត្តផ្កានេះខ្លាំងបំផុត។ មូលហេតុគឺថាពេលខ្ញុំមើលផ្កានេះក្នុងពេលដែលខ្ញុំមានភាពតានតឹងពីការសិក្សា ពេលខ្ញុំឈឺចិត្ត ឬពេលខ្ញុំបាក់ទឹកចិត្ត ផ្កានេះវាធ្វើអោយខ្ញុំមានអារម្មណ៍ប្រសើរឡើងវិញ។



ចូលចិត្តផ្កា:
**ចន្ទ**

ឈ្មោះ : ធិន សុណា
ភេទ : ប្រុស
អាយុ : 20
ការងារ : សិស្ស

គឺរីកនៅចុងរដូវត្រជាក់បំផុត និងដើមរដូវក្តៅ។ ផ្កានិទាឃរដូវនេះជូនដំណឹងអំពីការចាប់ផ្តើមនៃឆមាសថ្មីរបស់សាលារៀន ឬការចាប់ផ្តើមចូលធ្វើការងារក្រុមហ៊ុននានា។ ថ្វីត្បិតមានតែក្នុងប្រទេសជប៉ុនប៉ុណ្ណោះដែលអាចមើលឃើញផ្កា SAKURA ក៏ដោយតែមានពេលខ្លះខ្ញុំគិតថាវាជាការប្រសើរណាស់ ប្រសិនបើមានប្រពៃណីគយគន់ផ្កានៅក្នុងប្រទេសកម្ពុជា។ ការសម្រាកកាយហើយចំណាយពេលជាមួយមិត្តភក្តិ និងគ្រួសាររបស់ខ្ញុំនៅក្រោមដើម SAKURA គឺជាពេលវេលាដ៏ល្អបំផុតសម្រាប់ខ្ញុំ។






ឈ្មោះ : ម៉ៅ ធារិទ្ធ
ភេទ : ប្រុស
អាយុ : 26
ការងារ : បុគ្គលិកក្រុមហ៊ុន

ពណ៌ទាំងពីរនេះតំណាងនៃសេចក្តីស្រលាញ់ និងភាពស្មោះត្រង់ ហើយតំណាងភាពបរិសុទ្ធ ម៉្យាងទៀតវាតំណាងសន្តិភាព នៅពេលខ្ញុំលំបាកចូលមើលផ្កាជានិច្ច។





ឈ្មោះ : គ្រាញ់ នោរា
ភេទ : ស្រី
អាយុ : 23
ការងារ : បុគ្គលិកខាងញញឹម

ចូលចិត្តផ្កា:
**ផ្កាកុលាបពណ៌ក្រហម និងពណ៌ស**



ពីព្រោះផ្កាម្លិះជាផ្កាមួយប្រភេទដែលមានក្លិនក្រអូបឈ្ងុយពេលដែលប្រហើរក្លិនមកមានអារម្មណ៍ថាស្រស់ស្រាយ ផ្កាម្លិះតំណាងអោយភាពស្រស់ស្រាយ និងបរិសុទ្ធ។



ចូលចិត្តផ្កា:
**ផ្កាម្លិះ**

ឈ្មោះ : ម៉ាន ស្រីណែត
ភេទ : ស្រី
អាយុ : 23
ការងារ : បុគ្គលិកខាងញញឹម



ពីព្រោះផ្កាឈូកជាបុប្ផាដែលដុះនៅក្នុងដីភក់ ដែលមានសម្រស់ស្រស់ត្រកាលគួរជាទីគយគន់។ ផ្កាឈូកតែងតែត្រូវបានលើកតម្កើងនឹងជាគ្រឿងសក្ការៈក្នុងព្រះពុទ្ធសាសនា។ ហើយផ្កាឈូក គឺតំណាងអោយភាពស្មោះសរបរិសុទ្ធ។



ចូលចិត្តផ្កា:
**ផ្កាឈូក**

ឈ្មោះ : ប៊ុត ស្រីនិច
ភេទ : ស្រី
អាយុ : 21
ការងារ : បុគ្គលិកខាងញញឹម

# S ជប៉ុន Japanese ការប្រៀបធៀប

ចូលចិត្តផ្កា:
## SAKURA
Cherry-Blossoms



ខ្ញុំចូលចិត្តផ្កា SAKURA ពីព្រោះវាស្អាតជាពិសេសពេលដែលវាកំពុងរីក និងពេលដែលវាជ្រុះធ្លាក់តាមខ្យល់ដូចព្រិល។ ខ្ញុំនៅចងចាំជាពិសេស ពេលជានិស្សិតមហាវិទ្យាល័យខ្ញុំចូលចិត្តដើរតាមផ្លូវដើរអមដោយផ្កា SAKURA ដែលមានពន្លឺចែងចាំង។ វាគឺជាការចងចាំដ៏ល្អមួយ ពីព្រោះពេលនោះខ្ញុំបានដើរជាមួយមនុស្សដែលខ្ញុំស្រលាញ់។



ឈ្មោះ : ASAKURA keita
ភេទ : ប្រុស
អាយុ : 32
ការងារ : បុគ្គលិកក្រុមហ៊ុន

ចូលចិត្តផ្កា:
## SAKURA
Cherry-Blossoms
(នៅរដូវរងារ)



មានផ្កា SAKURA ដុះដាលនៅក្នុងរដូវរងារ (ពីខែតុលាដល់ ខែមករា)។ នៅពេលដែលខ្ញុំបានឃើញផ្កា SAKURA រដូវរងារជាលើកដំបូងខ្ញុំពិតជាភ្ញាក់ផ្អើលណាស់ដោយគិតថាហេតុអ្វីបានជាវារីកក្នុងអាកាសធាតុត្រជាក់អញ្ចឹង។ ការមើលនៅរដូវរងារដែលកំពុងខំប្រឹងរីកពេលមេឃស្រលះបានធ្វើអោយខ្លួនខ្ញុំក៏មានអារម្មណ៍ប្រឹងប្រែងបន្តទៅមុខទៀត។ ចាប់តាំងពីពេលនោះមក ខ្ញុំពិតជាចូលចិត្តផ្កា SAKURA រដូវរងារ។



ឈ្មោះ : FUKUDA Nobuhide
ភេទ : ប្រុស
អាយុ : 56
ការងារ : កំពុងស្វែងរកការងារថ្មី

ចូលចិត្តផ្កា:
## ផ្កា Sweetpea



កាលនៅជាសិស្សវិទ្យាល័យខ្ញុំបានច្រៀងចម្រៀង "Akai Sweetpea (ផ្កា Sweetpea ពណ៌ក្រហម)" ជាមួយមិត្តរួមថ្នាក់ជាជាច្រើននៅក្នុងការប្រកួតប្រជែង ហើយពួកយើងទទួលបានលេខ១ថែមទៀតផង។ ពួកយើងបានធ្វើការហ្វឹកហាត់យ៉ាងច្រើន ទើបការច្រៀងមានភាពស៊ីចង្វាក់គ្នា។ ខ្ញុំនៅតែមានអារម្មណ៍ជាមួយផ្កា Sweetpea ដែលនាំមកនូវសំណាង។



ឈ្មោះ : YAHAZU Ken
ភេទ : ប្រុស
អាយុ : ??
ការងារ : កំពុងស្វែងរកការងារថ្មី



គ្មានស្រីណាដែលថាមិនរីករាយទេជាមួយផ្កាកុលាបនោះ! ប្រសិនបើអ្នកទទួលបានផ្កាកុលាបពីសង្សា ដូចជាក្នុងខ្សែភាពយន្ត ..♡ នោះការពេញ-ចិត្តនឹងមានកាន់តែខ្លាំង។ បុរសគ្រប់គ្នាគួរជូនកាដូរនេះទៅមនុស្សស្រីដែលខ្លួនស្រលាញ់យ៉ាងម៉េចដែរ?

ចូលចិត្តផ្កា:
## ផ្កាកុលាប



ឈ្មោះ : OKUBO Rie
ភេទ : ស្រី
អាយុ : 25
ការងារ : ទាហានជើងទឹក



ចូលចិត្តផ្កា:
## ផ្កា Pansy

កាលពីខ្ញុំនៅក្មេងផ្កានេះ គឺមាននៅពីមុខទ្វារចូលផ្ទះរបស់ខ្ញុំ។ ផ្កានេះគឺជាផ្កាដែលខ្ញុំចូលចិត្ត ពីព្រោះវាមើលទៅហាក់ដូចជាមុខរបស់មនុស្សវាហាក់បីដូចជាមានភ្នែក មាត់។ ជាពិសេសផ្កាពណ៌ខៀវ មើលទៅដូចជាមុខរបស់មនុស្សដែលមានសភាពភ័យខ្លាចឬស្លេកស្លាំង។



ឈ្មោះ : ITO Yoko
ភេទ : ស្រី
អាយុ : 22
ការងារ : សិស្ស



ចូលចិត្តផ្កា:
## ផ្កា Gutsy Sunflower

ពីព្រោះតែផ្កាមួយប្រភេទនេះវាអាចទទួលរងនូវកំលាំងរបស់ខ្យល់ព្យុះ tsumami។ ផ្កាប្រភេទនេះមានដាំនូវតំបន់ Ishinomaki វាជាកន្លែងដែលកើតមាន tsumami កាលពីមុន។ ផ្កាឈូករត្ន័ប្រភេទនេះគឺដាំនូវខាងក្រោមក្លោងទ្វារ "Susu, Ishinomaki" មិត្តភក្តិរបស់ខ្ញុំគឺជាជំនាន់ទី៨ដែលមើលថែទាំផ្កានេះហើយផ្កានេះវាមានកំពស់ប្រហែល២ម៉ែត្រ។ ខ្ញុំតែងតែរំភើបនឹងសប្បាយចិត្តណាស់នៅពេលដែលបានឃើញរូបភាពផ្កានេះម្តងៗ។



ឈ្មោះ : GOTO Marina
ភេទ : ស្រី
អាយុ : 21
ការងារ : សិស្ស

## ការបញ្ចេញមតិជារួម:

ក្នុងចំណោម១២នាក់ មានជនជាតិខ្មែរ១នាក់ និងជប៉ុន២នាក់ដែលពួកគេចូលចិត្តផ្កា SAKURA។ វាជាប្រភេទផ្កាដ៏ពេញនិយមបំផុត! ក្រៅពីនេះមានជនជាតិខ្មែរខ្លះឆ្លើយថាពួកគេចូលចិត្តផ្កានៅជុំវិញផ្ទះ ហើយជនជាតិជប៉ុនបានឆ្លើយថាពួកគេចូលចិត្តផ្កាជាមួយនឹងការចងចាំនៅពេលមានលក្ខណៈពិសេសអ្វីមួយ។



### ចំនុចដែលគួរអោយចាប់អារម្មណ៍នៅប្រទេសជប៉ុន

# សេវាកម្មជួលមិត្តប្រុស

## RENTAL BOYFRIEND

ជ្រើសបុរសដែលអ្នកចូលចិត្តពីគេហទំព័រ



វាជារឿងសាមញ្ញមួយ នៅក្នុងប្រទេសជប៉ុនគេអាចរកជួលបាននៅឧបករណ៍ប្រើប្រាស់មួយចំនួនដូចជា៖ រថយន្ត, គ្រឿងសង្ហារឹម, គ្រឿងប្រើប្រាស់ក្នុងផ្ទះ, ឌីវីឌីជាដើម។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយនាពេលថ្មីៗនេះ គេអាចជួលបានទៅដល់ "មិត្តប្រុស"។ ប្រធានបទ "សេវាកម្មជួលមិត្តប្រុស" គឺជាសេវាកម្មដែលអ្នកជួលបុរសវ័យជំទង់នៅពេលដែលអ្នកចង់ធ្វើការណាត់ជួបដើម្បីធ្វើអោយអ្នកមានអារម្មណ៍ស្រស់ស្រាយ។ ក្នុងរយៈពេលកន្លងមកនេះ យើងសង្កេតឃើញថាបុរសដែលមានអាយុខ្ទង់៦០ឆ្នាំតែងប្រើប្រាស់សេវាកម្មស្វែងរកស្រ្តីជាដៃគូ ដែលភាគច្រើននៃស្រ្តីទាំងនោះគឺមានវ័យក្មេងៗ និងស្រស់ស្អាត ហើយវាពិតជាមានប្រជាប្រិយភាពខ្លាំងបំផុត។ រាល់ការណាត់ជួបម្តងៗ គេត្រូវចំណាយតម្លៃចាប់ពី 4.000 ទៅ 7.000 យ៉េននៅក្នុងមួយម៉ោង។ យ៉ាងណាមិញ នៅមានការចំណាយផ្សេងៗមួយចំនួនទៀតផងដែរ។ "ខ្ញុំចង់ទទួលបានការថ្នាក់ថ្នមល្អបំផុតពីបុរសម្នាក់", "ដោយសារតែខ្ញុំពុំធ្លាប់បានមានមិត្តប្រុស ឬទទួលបានការបង្ហាញពីសេចក្តីស្រលាញ់ ឬការថ្នាក់ថ្នមពីបុរសណាម្នាក់ឡើយ"។ ក្មេងស្រីជាច្រើននៅកម្ពុជាជាច្រើនបាននិយាយថា៖ ខ្ញុំពិតជាមិនត្រូវការសេវាកម្មមួយនេះទេ ពីព្រោះខ្ញុំមានមិត្តប្រុសរួចហើយ។ តើអ្នកចង់ប្រើប្រាស់សេវាកម្មនេះដែរទេ ?

- ឧទាហរណ៍៖ ប្រសិនបើទទួលអាហារពេលល្ងាច (2 ម៉ោង) វាមានប្រហែល 15.000 ទៅ 20.000 យ៉េន (ប្រហែល 150 ទៅ 200 ដុល្លារអាមេរិក)
- ដោយសារតែវាជារឿងមួយដែលរីករាយនឹងការណាត់ជួប ប៉ុន្តែបើនិយាយពីការប៉ះរាងកាយហួសកំរិតគឺ NG!



Website: 2013(C) レンタル彼氏PREMIUM Inc.


★ អាចកម្មង់អាហារតាមប្រព័ន្ធអ៊ីនធឺណែត និងដឹកជញ្ជូនដល់កន្លែង → http://sushibar-kh.com




មានបន្ទប់ VIP ជាច្រើនទាំងសាខាទី១ និងទី២ រួមជាមួយ ទីធ្លាចតឡានធំទូលាយ!!

សេវាកម្មកម្មង់អាហារតាមប្រព័ន្ធអ៊ីនធឺណែត និងដឹកជញ្ជូនដល់កន្លែងយ៉ាងងាយស្រួល!!

សូមចូលតាមវេបសាយនេះ http://www.sushibar-kh.com

● បន្ទាប់ពីធ្វើការកម្មង់រួច នឹងមានបុគ្គលិកធ្វើការទំនាក់ទំនងបញ្ជាក់ភ្លាមៗ

THE SUSHI BAR 1-BKK
Add: No.2D, St.302, Boeung Keng kang 1, Phnom Penh
Tel: 023-726-438, 023-726-439
OPEN: 11:00~22:00 (អាចកម្មង់បានត្រឹមម៉ោង 21:30)

THE SUSHI BAR 2-CCV
Add: No.74, St. Tonle Sap, Chroy Chong Var, Phnom Penh ◀ នៅជិត Bellevue Serviced Apartment
Tel: 023-432-307, 023-432-308
OPEN: 11:00~22:00 (អាចកម្មង់បានត្រឹមម៉ោង 21:30)




JCGroup អគ្គនាយកប្រតិបត្តិ ( President CEO )

## លោក Ko Honam

### តើសព្វថ្ងៃនេះលោកធ្វើអាជីវកម្មបែបណានៅក្នុងកម្ពុជា ?

កន្លងមកនេះខ្ញុំបានគ្រប់គ្រងក្រុមហ៊ុនដែលហៅថា “JCAC ( JC Agriculture Cooperatives) ”។ AC សំដៅទៅលើណូក្យូនៅប្រទេសជប៉ុន ហើយ JCAC គឺជាក្រុមហ៊ុនដែលផ្តល់សេវាកម្មយ៉ាងទូលំទូលាយជូនដល់កសិករ ដែលមានសកម្មភាពចម្បងគឺនាំចូល និងលក់នូវគ្រឿងចក្របុ្ធសំភារៈកសិកម្ម។ លើសពីនេះ ក្នុងពេលថ្មីៗយើងបានស្ថាបនានូវស្ថាប័នហិរញ្ញវត្ថុដែលបានទទួលអាជ្ញាប័ណ្ណជាផ្លូវការ ដើម្បីផ្តល់សេវាកម្មហិរញ្ញវត្ថុដូចជាកម្មវិធីកម្ចីជូនដល់ប្រជាកសិករដែលមានឈ្មោះថា “JC Finance” ដែរ ដែលជាសរុបខ្ញុំកំពុងប្រតិបត្តិ និងគ្រប់គ្រងនូវក្រុមហ៊ុនចំនួន២។

នៅប្រទេសជប៉ុនតាំងពីដើមមានអង្គភាពដ៏ធំមួយដែលហៅថា “ណូក្យូ” ដែលក្នុងនោះ មានអង្គភាពដែលមានតួនាទីការប្រមូល និងលក់នូវកសិផលនៅទូទាំងប្រទេសដែលហៅថា “សហព័ន្ធណូក្យូទូទាំងប្រទេស” និងអង្គភាពដែលមានមុខងារដូចធនាគារសម្រាប់ប្រជាកសិករ ដែលមានឈ្មោះថា “បេឡាកណ្តាលកសិកម្ម និងរុក្ខា”។ មូលហេតុនៃការអភិវឌ្ឍន៍វប្បធម៌កសិកម្មនៅប្រទេសជប៉ុនអោយមាននៅក្នុងពិភពលោកនេះ គឺដោយសារមានវត្តមាននៃអង្គភាពទាំងពីរខាងលើហ្នឹងហើយ។

ដូចប្រទេសជប៉ុន ប្រទេសកម្ពុជាជាប្រទេសមួយដែលពោរពេញទៅដោយសកម្មភាពកសិកម្ម ក៏ធ្លាប់មានអង្គភាពដូចណូក្យូដែរ តែវាមិនបានវិវឌ្ឍន៍ដូចអង្គភាពខ្នាតធំរឹងមាំនៅប្រទេសជប៉ុនឡើយ។ យើងខ្ញុំនឹងតស៊ូបង្កើតប្រព័ន្ធធំដូចណូក្យូជប៉ុនតាមរយៈក្រុមហ៊ុនទាំងពីរខាងលើដើម្បីនាំអោយកសិករមានចំណូលប្រកបដោយស្ថេរភាព។

### មូលហេតុអ្វីបានជាលោកបានមកប្រទេសកម្ពុជា ?

កាលពីដើម ខ្ញុំបានទទួលបន្ទុកការជំរុញវិនិយោគរបស់សហគ្រាសជប៉ុននៅក្នុងទឹកដីអាស៊ីអាគ្នេយ៍ ក្នុងនាមជាក្រុមប្រឹក្សាភិបាលម្នាក់ក្នុងក្រុមហ៊ុនប្រឹក្សាយោបល់ជាយុទ្ធសាស្រ្ត និងផ្តល់មូលធនសម្រាប់ក្រុមហ៊ុនបង្កើតថ្មីឡើងនៅប្រទេសជប៉ុន។ កាលពី១០ឆ្នាំមុន ខ្ញុំបានមកបំពេញបេសកកម្មនៅក្រុងហូជីមីញ ហើយមានឱកាសមកប្រទេសកម្ពុជាក្នុងគោលបំណងការសិក្សា ហើយក៏បានឃើញនូវសក្តានុពលដោយសារមានហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្មក៏សម្រេចចិត្តបង្កើតក្រុមហ៊ុនតែម្តង។

### តើលោកបានធ្វើអ្វីខ្លះបន្ទាប់ពីបានមកប្រទេសកម្ពុជា ?

ចាប់ពីឆ្នាំ២០០៩ ខ្ញុំបានសាកល្បងធ្វើកសិកម្មដាំស្រូវដោយជួលដីស្រែ ២៣០ហិកតានៅខេត្តបាត់ដំបូង។ យើងបានប្រើប្រាស់គោយន្តផ្ទាល់ខ្លួន ក៏បានធ្វើការទទួលការងារភ្ជួរស្រែនិងជួលគ្រឿងកសិកម្មដោយមានអ្នកបញ្ជាបន្ទាប់ពីបានភ្ជួរដីរបស់ខ្លួនរួច។ ទន្ទឹមនឹងនេះ យើងបានឃើញពីភាពប្រែប្រួលនៃតម្រូវការរបស់ប្រជាកសិករពី “ចង់ជួល” គ្រឿងកសិកម្មទៅជា “ចង់ទិញ” ដែរ។

ជាទូទៅប្រជាកសិករមានចំណូលគ្រប់គ្រាន់ ក្រោយពេលបានប្រមូលកសិផលហើយ តែក្នុងរយៈពេលមួយធំរហូតដល់ប្រមូលផលនោះ ពួកគេតែងតែជួបវិបត្តិសេដ្ឋកិច្ចដែរ។ ដូច្នេះយើងខ្ញុំបានប្តូរគំនិតថា មិនមែនធ្វើកសិកម្មដោយខ្លួនយើងទេគឺគួរធ្វើការផ្តល់សេវាកម្មឬគ្រឿងឧបករណ៍នានាដោយភ្ជាប់ជាមួយកម្មវិធីកម្ចីជូនដល់ប្រជាកសិករវិញ ហើយរហូតដល់ពេលនេះយើងមានសេវាកម្មការជួលនិងលក់ដោយប្រាក់កម្ចីនូវគ្រឿងកសិកម្មដែរ។ នេះគឺជាប្រការមួយដូចគ្នានឹងប្រព័ន្ធណូក្យូជប៉ុនពីដើម ដែលមានតួនាទីអនុវត្តកិច្ចការណាកសិករមិនអាចធ្វើបាន។ ម៉្យាងទៀត យើងព្យាយាមផ្តល់សេវាកម្មទាំងយប់ទាំងថ្ងៃនិងថ្ងៃសៅរ៍អាទិត្យ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការទំនាក់ទំនងពីប្រជាកសិករ ព្រមទាំងផ្តល់ភាពងាយស្រួលក្នុងការសងប្រាក់របស់កសិករនៅដាច់ស្រយោល ដោយធ្វើការសហការជាមួយក្រុមហ៊ុនWING គឺយើងខ្ញុំយកចិត្តទុកដាក់នូវផលប្រយោជន៍របស់កសិករជាចម្បង។

### ប្រការយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងធនធានមនុស្ស

នៅពេលធ្វើការសន្ទនាជាមួយបុគ្គលិក ខ្ញុំតែងតែគិតព្រាងទុករបៀបប្រាប់គេ។ ក្រុមហ៊ុនយើងអាចប្រព្រឹត្តអាជីវកម្មបាន គឺដោយសារមានការប្រឹងប្រែងរបស់បុគ្គលិកទាំងមូល។ យើងនឹងបង្រៀនបច្ចេកទេសជប៉ុនដល់បុគ្គលិកកម្ពុជា ហើយពួកគេក៏បង្រៀនយើងពីកម្ពុជាដែរ គឺខ្ញុំយកចិត្តទុកដាក់ជានិច្ចពីការគោរពទៅវិញទៅមកនិងប្រឹងប្រែងដោយឈរលើឆាកជាមួយគ្នា។

ម៉្យាងទៀត ក្រុមហ៊ុនយើងមានកម្មវិធីធ្វើដំណើរកម្សសិក្សាសម្រាប់បុគ្គលិកក្នុង១ឆ្នាំ៣ដង។ តាមរយៈប្រតិបត្តិការណ៍ទាំងឡាយនេះ ភាពសមាគ្គីក្នុងបុគ្គលិកនឹងកើនឡើង ហើយវានឹងក្លាយទៅជាមោទនភាពខ្លួនផង តភ្ជាប់នូវអភិវឌ្ឍន៍បុគ្គលម្នាក់ៗផងដែរ។

### សូមបង្ហាញទស្សនៈវិស័យនាថ្ងៃអនាគត

ចំពោះថ្ងៃមុខទៀត ខ្ញុំមានបំណងបង្កើតកម្មវិធីកម្ចីដែលពាក់ព័ន្ធនឹងក្រៅពីគ្រឿងកសិកម្ម ដូចជាជីឬសម្ភារៈកសិកម្មផ្សេងៗ ព្រមទាំងចង់បង្កើតកម្មវិធីកម្ចីសម្រាប់វិនិយោគកសាងធារាសាស្រ្ត ដើម្បីបង្កើតប្រព័ន្ធទឹកនៅជុំវិញស្រែកាន់តែល្អសម្រាប់អោយមានលទ្ធភាពប្រមូលផលនៅរដូវប្រាំង។

ម៉្យាងទៀត មានផែនការប្រើប្រាស់ឧបករណ៍Drone ដើម្បីពិនិត្យស្ថានភាពដីស្រែ ហើយទីបញ្ចប់អោយវាធ្វើការសាបថ្នាំកសិកម្មដើម្បីផ្តល់បរិស្ថានកសិកម្មដែលប្រជាកសិករប្រមូលអារម្មណ៍ចំពោះតែការថែទាំ និងដាំដុះ និងជំរុញបង្កើនប្រាក់ចំណូលបាន។

# EVENT INFORMATION & REPORT

## ព័ត៌មានព្រឹត្តិការណ៍ និងរបាយការណ៍








## “មហោស្រព គីហ្សូណា ជប៉ុន-កម្ពុជា ២០១៨” ត្រូវបានប្រារព្ធធ្វើនៅ CJCC រាជធានីភ្នំពេញ!

តើអ្នកដឹងទេថា "មហោស្រព គីហ្សូណា ជប៉ុន-កម្ពុជា ( KIZUNA FESTIVAL )"? វាជាព្រឹត្តិការណ៍ដ៏ធំមួយដែលនាំមកនូវវប្បធម៌ប្រពៃណីនិងទំនៀមទំលាប់ថ្មីៗ វាត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំនៅជុំវិញរដូវកាលនេះ ចាប់តាំងពីឆ្នាំ 2012។ និង "មហោស្រព គីហ្សូណា ជប៉ុន-កម្ពុជា" លើកទី 7 ត្រូវបានប្រារព្ធធ្វើនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន (CJCC) នៅទីក្រុងភ្នំពេញ ពីថ្ងៃទី 22 ដល់ថ្ងៃទី 25 ខែកុម្ភៈ។

នៅពិធីបើកនៅថ្ងៃទី 22 ខែកុម្ភៈ មានការប្រគុំតន្ត្រីពីរត្រូវបានប្រារព្ធឡើងមួយគឺការប្រគំតន្ត្រី “Gagaku” ដែលលេងដោយព្រះសង្ឃជប៉ុនហើយមួយទៀតគឺការប្រគុំតន្ត្រី "Wa-daiko"។ ហើយមិនត្រឹមតែការប្រគុំតន្ត្រីនេះទេ មានព្រឹត្តិការណ៍ជាច្រើនក្នុងអំឡុងពេលពិធីបុណ្យនេះ ដូចជារោងមហោស្រពម៉ាច Match Flag ដើម្បីធ្វើទង់ជាតិធំ ៗ ដោយអ្នកចូលរួមកម្ពុជា និងជប៉ុនរួមគ្នាបញ្ចាំងខ្សែភាពយន្តជប៉ុន ការបង្ហាញពីរបៀបស្លៀកពាក់បែបតុក្កតាជប៉ុន កីឡាយុទ្ធសិល្បជប៉ុន និងកម្ពុជា។ល។ ហើយក៏មានការតាំងពិព័រណ៍បង្ហាញពីសកម្មភាពនៅក្នុងប្រទេសកម្ពុជាដោយ JICA អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនជប៉ុនក៏ត្រូវបានប្រារព្ធធ្វើផងដែរ។ មានការតាំងលក់ម្ហូបអាហារ និងភេសជ្ជៈជាច្រើននៅខាងក្រៅ។ មនុស្សជាច្រើនបានមកចូលរួមក្នុងព្រឹត្តិការណ៍ដ៏ធំនេះ។













# ពិព័រណ៍កម្ពុជា ២០១៨

## cambodia festival

65th Anniversary of Diplomatic Relations between JAPAN & CAMBODIA

# カンボジアフェスティバル 2018





សូមស្វាគមន៍ និងអញ្ជើញចូលរួម “ពិព័រណ៍កម្ពុជា២០១៨” អោយបានច្រើនកុះករ ។

**5/3 Thu · 4 Fri**

**at TOKYO, JAPAN**



## គោលបំណងនៃការរៀបចំពិព័រណ៍កម្ពុជា

“ពិព័រណ៍កម្ពុជា” ត្រូវបានផ្តួចផ្តើមឡើងដោយសហគមន៍ខ្មែរប្រចាំប្រទេសជប៉ុន និងត្រូវបានសហការរៀបចំប្រារព្ធជាលើកដំបូង ដោយឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន និងសហគមន៍ខ្មែរ ហើយមានការចូលរួមចំណែកសហការផងដែរពីសមាគមនិស្សិតខ្មែរប្រចាំប្រទេសជប៉ុន និងជនជាតិជប៉ុនដែលស្រឡាញ់ប្រទេសកម្ពុជា ដើម្បីអបអរសាទរការរំលឹក “ខួបទី៦០នៃសន្ធិសញ្ញាមេត្រីភាពរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន” កាលពីឆ្នាំ២០១៥ នៅឧទ្យានយ៉ុយ៉ុគីនៅទីក្រុងតូក្យូ ។

“ពិព័រណ៍កម្ពុជា” ដែលមានរយៈពេលពីរថ្ងៃ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយវប្បធម៌ប្រពៃណីខ្មែរបង្ហាញពីវិស័យសក្តានុពលទេសចរណ៍ក៏ដូចជាសេដ្ឋកិច្ចកម្ពុជាដើម្បីជម្រុញអោយអ្នកទេសចរណ៍ និងវិនិយោគិនជប៉ុនទៅប្រទេសកម្ពុជា ព្រមទាំងពង្រឹងមិត្តភាពកម្ពុជា-ជប៉ុនផងដែរ ។

លើសពីនេះពិព័រណ៍កម្ពុជា ផ្តល់ឱកាសដ៏ល្អបំផុតដល់អ្នកចូលរួមទាំងអស់ អញ្ជើញទស្សនាតាមស្តង់នានាជាច្រើន ភ្លក់ម្ហូបអាហារខ្មែរ រីករាយទស្សនារបាំប្រពៃណីខ្មែរសំដែងដោយក្រុមរបាំមកពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈកម្ពុជា ចំរៀងខ្មែរច្រៀងដោយអ្នកចំរៀងល្បីៗមកពីប្រទេសកម្ពុជា ការបង្ហាញម៉ូតសំលៀកបំពាក់ខ្មែរ និងកម្មវិធីវប្បធម៌ចំរុះជាច្រើនដ៏ទៃទៀត។

នៅឆ្នាំ២០១៧ យើងបានសហការរៀបចំការតាំង “ពិព័រណ៍កម្ពុជា២០១៧” នៅឧទ្យានយ៉ុយ៉ុគី ដែលជាពិព័រណ៍កម្ពុជាលើកទីបី និងដ៏ធំបើប្រៀបធៀបពិព័រណ៍កម្ពុជា២០១៥ និង២០១៦ ហើយបានទទួលភ្ញៀវចូលរួមទស្សនាចំនួនជាង ១00,000 នាក់ ។





សម្រាប់ឆ្នាំ២០១៨ នេះ ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសជប៉ុន និងគណៈកម្មាធិការពិព័រណ៍កម្ពុជា រួមមានសមាគមនិស្សិតខ្មែរប្រចាំប្រទេសជប៉ុន និងជនជាតិជប៉ុនដែលស្រឡាញ់ប្រទេសកម្ពុជា នឹងសហការរៀបចំ “ពិព័រណ៍កម្ពុជា២០១៨” នៅថ្ងៃទី៣-៤ ខែឧសភា ឆ្នាំ២០១៨ នៅឧទ្យានយ៉ុយ៉ុគី នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ដើម្បីប្រារព្ធ “ខួបទី៦៥នៃការបង្កើតទំនាក់ទំនងការទូតកម្ពុជា-ជប៉ុន”។ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមសំដែងនូវកិច្ចស្វាគមន៍ និងដោយស្មោះស្ម័គ្រដល់ឯកឧត្តមលោកជំទាវ អស់លោក លោកស្រី អញ្ជើញចូលរួម និងគាំទ្រ “ពិព័រណ៍កម្ពុជា២០១៨” អោយបានច្រើនកុះករ និងជោគជ័យ ។







※នេះជារូបថតនៃទិដ្ឋភាពកាលពីឆ្នាំមុន

**កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃ “ពិព័រណ៍កម្ពុជា២០១៨”**

វេលា: ថ្ងៃទី៣~ទី៤ ខែឧសភាឆ្នាំ២០១៨ ចាប់ពីម៉ោង ១០:០០~១៩:០០

ទីតាំង: នៅឧទ្យានយ៉ុយ៉ុគិនៅទីក្រុងតូក្យូ ( កន្លែងតាំងពិព័រណ៍ + ឆាកសំដែង )

Official site : http://www.cambodiafestival.com

Fecebook : https://www.facebook.com/cambodiafestival

សូមចូលរួមទាំងអស់គ្នា

★អ្នកដែលជួលស្តង់

★អ្នកឧបត្ថម្ភ

កំពុងជ្រើសរើស !

# JAPAN in CAMBODIA

## ប្រទេសជប៉ុនដែលទទួលបទពិសោធន៍នៅកម្ពុជា






## Ken Clinic

នេះគឺជាគ្លីនិក ដែលស្ថាបនាឡើងដោយគ្រូពេទ្យជប៉ុនជាដំបូងបង្អស់នៅភ្នំពេញកាលពីឆ្នាំ២០១១ ដែលមានសេវាកម្មផ្នែករបួស ផ្នែកខាងក្នុងខ្លួន ផ្នែកកុមារ ព្រមទាំងមានកម្មវិធីចាក់ថ្នាំបង្ការ និងពិនិត្យសុខភាពផងដែរ។ Dr. Ken OKUZAWA ដែលជានាយកគ្លីនិក និងជាវេជ្ជបណ្ឌិតណែនាំវិធីព្យាបាលស្នាមរបួសបានឆាប់ និងស្អាត ដែលហៅថា "វិធីព្យាបាលដោយភាពសើម" ហើយអ្នកជំងឺដែលធ្លាប់ទទួលវិធីព្យាបាលនេះក៏គាំទ្រផងដែរ។ ក្រៅពី Dr.Ken នៅគ្លីនិកមានគ្រូព្យាបាលសរសៃ និងគ្រូព្យាបាលម្ហូលវិទ្យាសាស្ត្រ ហើយអាចទទួលសេវាព្យាបាលគ្រេចកជើង ឬឈឺចង្កេះជាដើមបានដែរ។



● **INFO**

No.14A, St.370, Boeung Keng Kang 1,
Phnom Penh
Tel: 023-223-844, 023-223-843
*ម៉ោងក្រៅធ្វើការ: 012-865-039
**ម៉ោងសេវាកម្ម:**
ថ្ងៃចន្ទ - ថ្ងៃសៅរ៍ 8:30-13:00, 15:00-19:00
WEB (ភាសាអង់គ្លេស) :
www.kenclinic-cambodia.com/en/index.html


**SUN Pharmacy-jp**

Facebook QR

**ឱសថស្ថានដែលគ្រប់គ្រងដោយជនជាតិជប៉ុនបានបើកដំណើការនៅបឹងកេងកង1!** ឱសថ | គ្រឿងសម្អាង | ផលិតផលសុខភាព

ឱសថស្ថានរបស់យើងខ្ញុំ នឹងព្យាយាមបំពេញរាល់តំរូវការរបស់អស់លោកអ្នក។ ជាឱសថស្ថានមួយដែលលោកអ្នកអាចជឿទុកចិត្តបាន។

បើកនៅម៉ោង ច័ន្ទ-សុក្រ **8:30AM-8:30PM**
សៅរ៍-អាទិត្យ **8:30AM-8:00PM**

**Add: #8CE0, St.310, Boeung Keng Kang 1**
នៅទល់មុខ BURGER KING, ជាប់នឹង Gloria Jean's Coffees
**Shop Phone No. (023) 636 7878**






**ខេន គ្លីនិក**
**Ken Clinic**




**គ្លីនិកឯកជនជប៉ុនទីមួយនៅប្រទេសកម្ពុជា**

ខួបលើកទី៨ សូមអគុណអ្នកទាំងអស់គ្នា!

មានបំរើសេវា៖ ផ្នែកវះកាត់ ផ្នែកជំងឺទូទៅ ផ្នែកជំងឺកុមារ វាស់សម្ពាធឈាម ពិនិត្យឈាម វិភាគទឹកនោម ថតកាំរស្មីអ៊ិច ឆ្លុះអេកូ ឆ្លុះក្រពះ ជាដើម

មានសេវាចាក់ថ្នាំបង្ការជាច្រើនប្រភេទ ការព្យាបាលចំបងដោយថ្នាំជប៉ុន



អាចប្រើប័ណ្ណធានារ៉ាប់រងធ្វើដំណើរទៅក្រៅប្រទេស (ដោយមិនចាំបាច់មានសាច់ប្រាក់)
ម៉ោងធ្វើការ: ច័ន្ទ-សៅរ៍ 8:30~13:00, 15:00~19:00
ផ្ទះលេខ 14A ផ្លូវ 370 សង្កាត់បឹងកេងកង I ខ័ណ្ឌចំការមន ភ្នំពេញ
Tel: 023-223-843, 023-223-844 (ខ្មែរ /ជប៉ុន / អង់គ្លេស)
012-865-039 (ការពិគ្រោះយោបល់ក្រៅម៉ោងធ្វើការ) (ជប៉ុន / អង់គ្លេស)

# Hospital / Clinic ស្ថាប័នសុខាភិបាលមកពីជប៉ុននៅភ្នំពេញ

ការពិនិត្យសុខភាពនៅពេលអត់ស្រួលខ្លួន។ វាជាការងារមួយដែលមានការពាក់ព័ន្ធនឹងសុខភាព ទើបចង់ទទួលសេវាកម្មនៅកន្លែងណាគួរទុកចិត្ត។ នៅក្នុងរាជធានីភ្នំពេញមានស្ថាប័នសុខាភិបាលមកពីជប៉ុន តាំងពីមន្ទីពេទ្យទូទៅគ្លីនិក រហូតដល់ពេទ្យធ្មេញ ហើយយើងអាចទទួលសេវាកម្មពិនិត្យដោយគ្រូពេទ្យជនជាតិជប៉ុន ដែលមានបទពិសោធន៍ជាច្រើន។

នៅក្នុងពេលនេះយើងនឹងធ្វើការណែនាំអំពីគ្លីនិកធ្មេញនៅក្នុងទីក្រុងភ្នំពេញ។



## Iwata Dental Clinic





នេះជាទន្តពេទ្យ ដែលមានទីតាំងនៅជាន់ទី១នៅក្នុង Royal Home Apartment នៅម្តុំបឹងកេងកង។ មានគ្រូជនជាតិជប៉ុន២នាក់ ជាគ្រូពេទ្យអចិន្ត្រៃយ៍ និងមិនមែនអចិន្ត្រៃយ៍ ហើយការពិនិត្យធ្មេញថាតើមានធ្មេញណាដែលចាំបាច់ព្យាបាលឬអត់ ដែលហៅថា “Check Up” គឺឥតគិតថ្លៃ។ គេមិនគិត Dr. Fee សម្រាប់ការព្យាបាលលើកទី១ ឬការពិនិត្យម្តងៗនៅឡើយ។ ដែលមានប្រព័ន្ធគិតថ្លៃសម្រាប់តែវិធីព្យាបាលដែលបានធ្វើប៉ុណ្ណោះ ទើបគិតក្នុងតម្លៃធូរថ្លៃ។





● **INFO**

in Royal Home Apartment (GF),
Corner of St.57 and St.360,
Boeung Keng Kang 1, Phnom Penh
Tel: 023-994-100
**ម៉ោងសេវាកម្ម**:
ថ្ងៃចន្ទ - ថ្ងៃសៅរ៍ 9:00-13:00, 14:00-18:00
Facebook: Iwata Dental Clinic



ត្រករកអ្វីដែលថ្មី
ជាមួយយើង !

# ហាងញុញ៉ឹម - NyoNyum Shop

## ហាងលក់វត្ថុអនុស្សាវរីយ៍ជាពិសេសតែផលិតផល “ ផលិតក្នុងប្រទេសកម្ពុជា ”



### សិប្បកម្មប្រពៃណី

យើងមានផលិតផលសិប្បកម្មធ្វើដោយដៃ
ដោយសិប្បករកម្ពុជាដែលតំណាងឲ្យកម្ពុជា



### ផលិតផលក្នុងស្រុក

យើងសំរិតសំរាំងយកតែផលិតផល
សរីរាង្គដែលចម្រាញ់ចេញពីដីនៅកម្ពុជា



### ផលិតផលសម្ផស្ស

ជាអំណោយដ៏ល្អសំរាប់សុភាពនារី។
យើងមានវត្ថុសំរាប់ជាអំណោយសម្ផស្សជាច្រើន។

### ហាងញុញ៉ឹម

- ផ្ទះលេខ៤ ផ្លូវលេខ៤៣២ សង្កាត់បឹងត្របែក ខណ្ឌចំការមន ក្រុងភ្នំពេញ
- ០២៣ ៧២៦ ២១៤
- ថ្ងៃច័ន្ទ ដល់ សុក្រ ម៉ោង០៩:០០ព្រឹក - ០៥:៣០ល្ងាច
  ( ថ្ងៃអាទិត្យ និងថ្ងៃបុណ្យជាតិ ឈប់សំរាក )
- NyoNyum Shop



### ហាងញុញ៉ឹមនៅក្នុងផ្សារទំនើបអ៊ីអន

- នៅជាន់ផ្ទាល់ដីផ្សារទំនើបអ៊ីអន
- រៀងរាល់ថ្ងៃ ម៉ោង០៨:០០ព្រឹក - ១០:០០យប់
- Souvenir Shop NyoNyum




សម្រាប់ខ្លួនឯង / សម្រាប់ជាអនុស្សាវរីយ៍



ក.ឆ
KChh
コンポンチュナン焼
កុលាភាជន៍ខេត្តកំពង់ឆ្នាំង

## យើងកំពុងផលិតកុលាភាជន៍នៅប្រទេសកម្ពុជា

អ្នកចង់បានគ្រឿងប្រើប្រាស់នៅលើតុ
និងគ្រឿងសង្ហារឹមដែរឬទេ ?

គ្រឿងប្រើប្រាស់នៅលើតុសម្រាប់
ភោជនីយដ្ឋាន គ្រឿងតុបតែង
សម្រាប់ហាង ឬបន្ទប់ទទួលភ្ញៀវ

យើងផលិតយ៉ាងផ្ចិតផ្ចង់តាមការកម្ម៉ង់ម៉ូត
និងពណ៌ពីលោកអ្នក។





### តើអ្វីទៅជាកុលាភាជន៍ខេត្តកំពង់ឆ្នាំង ?

វាគឺជាឈ្មោះ ( brand name )គម្រោងកុលាភាជន៍ខេត្តកំពង់ឆ្នាំងជាអ្នកបង្កើត។ គម្រោងនេះកំពុងខិតខំធ្វើឲ្យវប្បធម៌ខ្មែរដ៏រុងរឿង និងបច្ចេកទេសតាំងពីសម័យបុរាណកាលរស់ឡើងវិញជាលក្ខណៈប្រពៃណីថ្មីដែលស្របទៅនឹងរចនាបទជីវិតបែបសហសម័យព្រមទាំងកំពុងខិតខំផ្សព្វផ្សាយឧស្សាហកម្មក្នុងស្រុក។

គ្រប់កុលាភាជន៍ទាំងអស់ផលិតដោយប្រើប្រាស់វត្ថុធាតុដើមធម្មជាតិដែលរកបាននៅខេត្តកំពង់ឆ្នាំង។

Contact us > phone: 089-687-071 / mail: kchh.pottery@gmail.com
Find our products at: NyoNyum Shop #4 St.432 Phnom Penh / NyoNyum Shop AEON / Gallery Shop in InterContinental Phnom Penh

NyoNyum Original

# អាវយឺតរូបហនុមាន

មាន៤ពណ៌

- ពណ៌ខៀវចាស់ រូបហនុមានពណ៌ស
- ពណ៌ខ្មៅ រូបហនុមានពណ៌ស
- ពណ៌ស រូបហនុមានពណ៌ត្នោត
- ពណ៌ស រូបហនុមានពណ៌ខ្មៅ



ពណ៌ថ្មី



$១០

ទំហំ: S / M / L / XL

**មានលក់នៅហាងញុញ៉ឹម**

៩:០០-១៧:៣០
ទូរស័ព្ទ: ០២៣-៧២៦-២១៤
#៤, ផ្លូវ.៤៣២, ភ្នំពេញ



*Try it Japanese Food!*

# សូមសាកល្បង ម្ហូបជប៉ុន!



**ការជ្រើសរើសគ្រឿងផ្សំ:**

## Pancake Mix

( ម្សៅចម្រុះសម្រាប់ Pancake )

ម្សៅ "Pancake mix" ( ហៅថា "Hot-cake mix" នៅក្នុងប្រទេសជប៉ុន ) គឺជាម្សៅសម្រាប់ធ្វើនំ។ ម្សៅនេះត្រូវបានលាយរួចជាស្រេចអាចអោយអ្នកងាយស្រួលក្នុងការធ្វើនំជាមួយម្សៅនេះ។ ហើយមិនត្រឹមតែសំរាប់ធ្វើនំ Pancake ទេអ្នកក៏អាចប្រើនំនេះសម្រាប់នំជប៉ុនផងដែរ។

## មុខម្ហូប

## Dorayaki

"Dorayaki" គឺជានំបែបជប៉ុនដែលមានដាក់ស្ងួលសណ្តែកផ្អែម។



## គ្រឿងផ្សំ ( សម្រាប់ ៤ចំណែក )

| | |
|---|---|
| ម្សៅ ( បញ្ចូលគ្នាសម្រាប់នំ Pancake ) | 90g |
| ពងមាន់ | 1 |
| ទឹកឃ្មុំ | 1 ស្លាបព្រា |
| ស្រាជប៉ុនផ្អែម ( សម្រាប់ចម្អិនអាហារ ) | 1 ស្លាបព |
| ស្ករ | 40g |
| ទឹក | 60cc |
| បិទភ្ជាប់សណ្តែកក្រហមផ្អែម | 120g |

## វិធីធ្វើ

១. វាយពងដាក់ក្នុងចានមួយ ហើយបន្ថែមទឹកឃ្មុំ ស្រាជប៉ុនផ្អែម ស្ករ និងទឹក បន្ទាប់មកលាយវាឱ្យសព្វបានល្អ។

២. បន្ថែមម្សៅ Pancake ទៅក្នុងចានហើយលាយវា។

៣. ដាក់ឆ្នាំងអោយក្តៅ រួចដួសម្សៅដែលលាយរួចនោះចូល។

*សូមដាក់ប្រេងបន្តិចក្នុងចានមុនពេលកម្តៅ។

៤. ចំអិនរយៈពេល២នាទី និងឃើញមានឡើងពពុះរួចត្រឡប់វាទុកប្រហែល ១នាទី ទើបដួសវាចេញជាការស្រេច។ សូមធ្វើវាអោយបានចំនួន៨បន្ទះ។

៥. យកបន្ទះនំ Pancake ២មកដាក់ស្ងួលសណ្តែកក្រហម ដាក់នៅចន្លោះនំ រួចបិតវាអោយជាប់ជាការស្រេច។

គ្រឿងផ្សំដោយ: **Nisshin Seifun Group inc.**

សហការជាមួយ **Daishin Trading (Cambodia) Co., LTD.**






# Report from Japan

## ការរាយការណ៍ពីប្រទេសជប៉ុន





# ទីបំផុត ខ្ញុំបានមកដល់ប្រទេសជប៉ុន ! សំណូមពររបស់ខ្ញុំគឺ ...







ខ្ញុំបាទឈ្មោះ ផាន់ ផល្លី ជាជនជាតិខ្មែរមានអាយុ ២៦ឆ្នាំ នៅភូមិកោះចេក ឃុំ កោះចេក ស្រុក ពាមជរ ខេត្ត ព្រៃវែង។

ខ្ញុំបាទតែងមានបំណងចង់មកធ្វើការនៅប្រទេសជប៉ុន ព្រោះចិត្តរបស់ខ្ញុំបានមកប្រទេសជប៉ុនជាយូមកហើយ។ ប្រទេសជប៉ុនតែងតែជួយដល់ប្រទេសកំណើតរបស់ខ្ញុំ( កម្ពុជា )រហូតមកខ្ញុំក៏បានសំរេចចិត្តថា និងព្យាយាមយ៉ាងណាដើម្បីបានមកធ្វើការនៅប្រទេសជប៉ុន។ នៅស្រុកខ្មែរពិតមែនតែមានក្រុមហ៊ុនជាច្រើន តែនៅក្នុងចំណោមក្រុមហ៊ុនទាំងអស់ខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសយកក្រុមហ៊ុន IIS ពីព្រោះជាក្រុមហ៊ុនបានផ្តល់ទំនុកចិត្តដល់ខ្ញុំបាទ។ ជាពិសេសក្រុមហ៊ុន IIS គឺមានបទពិសោធន៍ជាច្រើនឆ្នាំក្នុងការបញ្ជូនពលករមកធ្វើការនៅប្រទេសជប៉ុនពិតប្រាកដ ដោយគ្មានសង្ស័យអ្វីឡើយ។ សម្រាប់ខ្ញុំដោយការព្យាយាមរៀនភាសាជប៉ុនជាច្រើនខែ ខ្ញុំបានសម្ភាសន៍ជាប់មកធ្វើការនៅប្រទេសជប៉ុនតាមបំណង់របស់ខ្ញុំមែន។ ពេលមកដល់ប្រទេសជប៉ុនខ្ញុំបានធ្វើការនៅក្រុមហ៊ុនសំណង់មួយកន្លែង។ ប្រទេសជប៉ុនជាប្រទេសដែលគោរពពេលវេលា និងច្បាប់ការងារយ៉ាងម៉ឹងម៉ាត់ រយៈពេលដំបូងខ្ញុំបាទមានការលំបាក និងសំរបតាមការងារទាំងអស់ណាស់ តែចិត្តរបស់ខ្ញុំមិនព្រមចុះចាញ់ មកដល់ពេលនេះការពិបាកក៏នៅតែមានសម្រាប់ខ្ញុំដែរ ទីមួយគឺ ភាសាតែម្តង។ តែខ្ញុំនៅព្យាយាមធ្វើការ និងរៀនភាសាបន្ថែមទៀតទៅតាមលទ្ធភាពដែលអាចទៅរួច។

ខ្ញុំបាទមានពាក្យចង់ផ្តាំទៅបងប្អូនខ្មែរយើងទាំងអស់ដែលមានបំណងចង់ធ្វើការនៅប្រទេសជប៉ុនថា ជំហានដំបូងយើងត្រូវតែរៀនភាសាជប៉ុនទាំងអស់គ្នា ដើម្បីមានភាពងាយស្រួលក្នុងការងាររបស់យើង។



សរសេរដោយ:

**ផាន់ ផល្លី**

ធ្វើការនៅក្រុមហ៊ុនសំណងនៅជប៉ុន



# មូលហេតុអ្វីបានជា បងយ៉ូគី មកប្រទេសកម្ពុជា ?

**បងយូគី**
ជាជនជាតិជប៉ុនដែលរស់នៅប្រទេសកម្ពុជា២៤ឆ្នាំ។ ធ្វើការជាអ្នកបកប្រែភាសាខ្មែរ-ជប៉ុន។ ជានិច្ចជាកាលរវល់រត់ធ្វើការពីនេះ ពីនោះមិនដែលឈប់។



នៅក្នុងការរស់នៅប្រឹទេសគេយូរៗទៅដឹងពីសង្គមនោះកាន់តែជ្រៅ។រឿងរ៉ាវខ្លះគួរឱ្យសើចរឿងខ្លះកំសត់ជូរចត់។នេះគឺជាការសាកល្បងរៀបរាប់អ្វីដែល “បងយូគី”បានមើលឃើញនៅក្នុងសង្គមខ្មែរ។

## ប្រការភ្ញាក់ផ្អើលស្តីពីភាពខុសគ្នានៃទម្លាប់ជីវភាពរវាងជប៉ុននិងកម្ពុជា
( តពីលេខមុន )

ក្រោយពេលបានសន្ទនាជាមួយអាពីងមួយរយៈរួចហើយ កូនប្រុសទាំងពីរនាក់ក៏បានវិលត្រឡប់ពីសាលារៀនជាបន្តបន្ទាប់។ ខ្ញុំសង្កេតឃើញថាក្រោយពេល ដាក់កាបូបហើយពួកគាត់ទៅបន្ទប់ទឹកដើម្បីមុជទឹកភ្លាមរួចហើយជួយកិច្ចការផ្ទះ ដូចជាធ្វើម្ហូប រៀបចំកន្លែងទទួលទានបាយ( កន្ទេល ) បូមទឹក ( កាលពីពេលនោះពុំទាន់មានទឹកពីក្បាលម៉ាស៊ីនឡើយ )ជាដើម។ ចំពោះកូនប្រុសហាក់ដូចជាមានពេលចេញទៅលេងខាងក្រៅ តែជាពិសេសកូនស្រីគឺពុំមានពេលវេលាចេញទៅលេងសោះ។ ខ្ញុំបាននឹកពីកាលពីខ្ញុំនៅរៀន បន្ទាប់ពីចេញពីសាលារៀនហើយខ្ញុំតែងតែលេងនៅខាងក្រៅជាមួយមិត្តភក្តិ ហើយល្ងាចបន្តិចទើបវិលត្រឡប់មកផ្ទះវិញ។ ហើយមិនសូវជួយកិច្ចការផ្ទះទេ គឺមើលទូរទស្សន៍ អានសៀវភៅ លេងតុក្កតាជាដើម ហើយរង់ចាំម្តាយមកពីធ្វើការ និងធ្វើម្ហូបអោយហូបប៉ុណ្ណោះ។

មួយទៀត នៅប្រទេសជប៉ុនខ្ញុំមានទម្លាប់មុជទឹកមុនសម្រាក់ដំណេក។ មិនដែលមុជទឹកនៅពេលវិលត្រឡប់មកពីខាងក្រៅភ្លាមៗទេ។ មានករណីពិសេសដែលរដូវក្តៅៗឬនៅពេលលេងកីឡាគឺមុជទឹកភ្លាមដែរ តែក្នុងជីវភាពទូទៅការមុជទឹកគឺជាអំពើមួយដែលត្រូវធ្វើនៅចុងក្រោយក្នុងមួយថ្ងៃៗ។ វាមានហេតុផលផ្សេងៗដែរ ដូចជានៅប្រទេសជប៉ុនអាកាសធាតុរងាហើយប្រជាជនចូលចិត្តមុជទឹកក្តៅ( ត្រាំខ្លួនក្នុងទឹកក្តៅ ) ដើម្បីសម្រួលចរន្តឈាម និងបង្កើនកម្តៅខ្លួនមុនចូលដំណេក។

នេះជាការចាប់ផ្តើមនៃការយល់ដឹងពីភាពខុសគ្នានៃទម្លាប់ជីវភាពរវាងជប៉ុន និងកម្ពុជា។ ចំពោះការមុជទឹកនេះ ខ្ញុំសម្រេចចិត្តធ្វើតាមកម្ពុជាវិញ គឺមកពីខាងក្រៅភ្លាមមុជទឹកភ្លាម។ ជាការពិតណាស់ការមុជទឹកបែបនេះពិតជាស្រួលខ្លួនមែន ដោយសារប្រទេសកម្ពុជាជាប្រទេសក្តៅហើយយើងតែងតែបែកញើសពេញក្នុងមួយថ្ងៃ។

ការភ្ញាក់ធំបំផុតគឺភាពខុសគ្នានៃទម្លាប់ក្នុងការបោកខោអាវ។ ខ្ញុំសង្កេតឃើញថា សមាជិកគ្រួសារម្នាក់ៗត្រូវបោកខោអាវរបស់ខ្លួនដោយរៀងៗខ្លួន។ នៅប្រទេសជប៉ុនជាធម្មតា បន្ទាប់ពីបានមុជទឹកហើយយើងដាក់ខោអាវនៅក្នុងម៉ាស៊ីនបោកខោអាវ ហើយម្តាយជាអ្នកបោកនៅព្រឹកថ្ងៃស្អែកឡើង។ ម្នាក់ៗមិនដែលបោកខោអាវដោយខ្លួនឯងទេ។ ជាការពិតណាស់កាលពីសម័យនោះពុំទាន់មានគេប្រើម៉ាស៊ីនបោកខោអាវនៅតាមផ្ទះប្រជាជនកម្ពុជាធម្មតាទេ ណាមួយអត់ទាន់មានភ្លើងប្រើប្រាស់ផង បើមានក៏ថ្លៃពេកអត់ហ៊ានប្រើ។ ដូច្នេះគេបោកខោអាវដោយដៃហើយបើទុកអោយម្តាយបោក វាជាបន្ទុកធ្ងន់ណាស់។ អញ្ចឹងហើយ សមាជិកគ្រួសារម្នាក់ៗបោកដោយខ្លួនឯង។



ការភ្ញាក់មួយទៀតគឺម៉ាស៊ីនទូទឹកកក។ នៅផ្ទះរបស់បងច័ន្ទលី ខ្ញុំឃើញមានម៉ាស៊ីនទូទឹកកកធំល្មមមួយតែគ្មានប្រើភ្លើង។ គេប្រើវាប្រដូចនឹងទូដាក់ចានឬត៉ូជាដើម។ នេះក៏បណ្តាលមកពីបញ្ហាភ្លើងហើយមើលទៅ។ ខ្ញុំសង្កេតឃើញថាម្តាយពីងតែងតែទៅផ្សារនៅពេលព្រឹកដើម្បីទិញបន្លែ សាច់សម្រាប់ក្នុងមួយថ្ងៃៗនោះ។ បងច័ន្ទលីក៏ទិញម្ហូបពីផ្សារមកហូបនៅពេលល្ងាចមួយពេល។ ពុំមានទម្លាប់ទិញសម្រាប់ស្តុកដើម្បីប្រើប្រាស់ប៉ុន្មានថ្ងៃឡើយ។ នៅប្រទេសជប៉ុនគេទៅផ្សារទំនើប ហើយទិញអ្វីៗសម្រាប់ហូបចុកសម្រាប់ប៉ុន្មានថ្ងៃ មិនដែលទៅផ្សារជារៀងរាល់ថ្ងៃទេ។

ខ្ញុំជាកូនជប៉ុនម្នាក់ដែលកើតនៅសម័យកាលដែលមានអ្វីៗទាំងអស់។ ដូច្នេះអ្វីដែលឃើញនៅទីនេះ គឺហាក់ដូចជាពិភពផ្សេង។ តែខ្ញុំក៏នឹកឃើញចំណេះដឹងដែលខ្ញុំធ្លាប់រៀន ឬមើលតាមទូរទស្សន៍ដែរថា ក្រោយសង្គ្រាមលោកលើកទី២ ប្រទេសជប៉ុនក៏ក្រីក្រដែរ ហើយប្រជាជនធម្មតាពុំមានលទ្ធភាពទិញម៉ាស៊ីនបោកខោអាវ ទូទឹកកកជាដើម។ ដែលជាបញ្ហាមួយសម្រាប់ស្ត្រីជាមេផ្ទះដែលទទួលបន្ទុកកិច្ចការផ្ទះ ( ការងារធ្ងន់ធ្ងរ និងត្រូវចំណាយពេលច្រើន )។ ហើយក្នុងសម័យកាលកំណើនសេដ្ឋកិច្ចនោះ ប្រជាជនខិតខំធ្វើការដើម្បីទិញគ្រឿងអេឡិចត្រូនិចទាំង៣គឺ “ទូរទស្សន៍” “ទូទឹកកក” និង “ម៉ាស៊ីនបោកខោអាវ” ហ្នឹងឯង។

( តទៅលេខក្រោយ )



NyoNyum
「この国」を伝える。カンボジア生活情報誌「ニョニュム」
Cambodian Life Navigation in Japanese and English
ញញឹម
ទស្សនាវដ្តីព័ត៌មានជីវភាពរស់នៅរបស់ប្រទេសកម្ពុជា
CONTACT
T: 012-500-052, 023-726-290 M: nyonyum@cisinc.co.jp
http://nyonyum.net/
បោះពុម្ពផ្សាយ: ២ខែម្តង (ថ្ងៃទី១០ ក្នុងខែគូ)
អំពីប្រទេសកម្ពុជារបស់យើង
ភាសាជប៉ុន / ភាសាអង់គ្លេស



# ហោរាសាស្ត្រប្រចាំខែ



ជូត

រាសីស្រុតចុះ។ **ការរកស៊ីៈ** ការរកស៊ីធ្លាក់ចុះខ្លាំង។ មិនត្រូវហ៊ានប្រថុយប្រថានក្នុងការបណ្ដាក់ទុនរកស៊ីដោយទ្រង់ទ្រាយធំឡើយ ហើយក៏មិនត្រូវប្រព្រឹត្តល្បែងស៊ីសងដែរ។ **ការងារៈ** ត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច បើមានគេមកបបួលរួមការងារជាមួយត្រូវចេះត្រិះរិះពិចារណាឱ្យបានល្អិតល្អន់។ **សេដ្ឋកិច្ចៈ** មិនត្រឹមតែមានចំណូលតិចតួចស្ដួចស្ដើងប៉ុណ្ណោះទេ ព្រមទាំងត្រូវជួបគ្រោះថ្នាក់ចាញ់បោកគេទៀតផង។ **សុខភាពៈ** មិនល្អជាទេ។ ត្រូវឆ្លៀតពេលសម្រាកឱ្យបានច្រើន។ **ស្នេហាៈ** ចំពោះគូស្នេហ៍ប្រយ័ត្នមានជនទី៣ ចូលមកជ្រៀតជ្រែក។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នអាចជួបគ្រោះថ្នាក់របួតដៃរអិលជើងធ្លាក់ពីទីខ្ពស់។

រាសីល្មមធ្យម។ **ការរកស៊ីៈ** ការរកស៊ីពិតមែនតែនៅជួបនឹងឧបស័គ្គខ្លះៗក្ដី ក៏មិនចោទជាបញ្ហាធ្ងន់ធ្ងរឡើយ។ **ការងារៈ** ចូរកុំធ្វេសប្រហែសឱ្យសោះ ជាពិសេសមុនពេលទទួលឬប្រគល់មុខទំនិញសព្វសារពើត្រូវចេះពិនិត្យមើលឱ្យបានច្បាស់លាស់។ **សេដ្ឋកិច្ចៈ** មានផលចំណូលច្រើនគួរសម។ តែត្រូវចេះកាត់បន្ថយនូវការចាយវាយពុំចាំបាច់ ទើបមិនប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ។ **សុខភាពៈ** នៅដើមខែមិនមានបញ្ហាអ្វីចោទធ្ងន់ធ្ងរឡើយ។ តែនៅចុងខែអាចមានជំងឺឈឺថ្កាត់ច្រើន។ **ស្នេហាៈ** ចំពោះគូស្នេហ៍ប្រយ័ត្នមានអ្នកក្រៅនាំរឿងមកអុជអាល។ **គ្រោះថ្នាក់ៈ** មិនគួរធ្វើដំណើរតាមផ្លូវទឹកឡើយ ។

រាសីល្មមធ្យម។ **ការរកស៊ីៈ** ពិតមែនតែងើបឡើងបន្តិចក្ដី។ តែក៏នៅជួបឧបសគ្គខ្លះៗដែរ។ ដូច្នេះមិនត្រូវហ៊ានប្រថុយប្រថានក្នុងការបណ្ដាក់ទុនរកស៊ីដោយទ្រង់ទ្រាយធំពេកទេ។ **ការងារៈ** ពិតមែនតែសម្ពាធការងារត្រូវបានធូរស្រាលខ្លះៗក្ដី តែទោះជាបានប្រកបការងារអ្វីគឺត្រូវមានស្មារតីប្រុងប្រយ័ត្នជាប់ជានិច្ច។ **សេដ្ឋកិច្ចៈ** មានផលចំណូលច្រើនគួរសមតែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះចាយវាយខ្ជោះខ្ជាយខ្លាំងពេក។ **សុខភាពៈ** មិនត្រូវល្មោភស៊ីល្មោភផឹកឡើយ ទើបមិនអន្តរាយដល់សុខភាពក្រពះ ពោះវៀន។ **ស្នេហាៈ** ចំពោះគូស្នេហ៍មានភាពស្និតស្នាលដូចប្រក្រតី។ **គ្រោះថ្នាក់ៈ** រលាកទឹកក្ដៅ ឬលង់ទឹក។

រាសីស្រុតចុះ។ **ការរកស៊ីៈ** បើមានជនចម្លែកយករបស់របរមានតម្លៃមកបញ្ចាំ ឬលក់ឱ្យចូរកុំទទួលឬទិញយកឱ្យសោះ។ ប្រយ័ត្នអាចជាប់ពាក់ព័ន្ធក្នុងបទល្មើសផ្សេងៗ។ **ការងារៈ** នៅពេលបំពេញការងារអ្វីមួយគឺមិនត្រូវយកខ្លួនទៅធានារឿងរបស់អ្នកដទៃឡើយ។ ប្រយ័ត្នធ្វើគុណបានទោស។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានផលចំណូលតិចតួច។ តែចំពោះទ្រព្យក្ដៅក្រហាយកុំលូកដៃទូលយកឱ្យសោះ ហើយក៏មិនត្រូវប្រព្រឹត្តល្បែងស៊ីសងដែរ។ **សុខភាពៈ** សុខភាពមិនល្អជាឡើយត្រូវយកចិត្តទុកដាក់ចំពោះនៃការហូបចុក។ **ស្នេហាៈ** ចំពោះគូស្នេហ៍ជួបរឿងរកាំរកូសច្រើន។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នពេលដើរឆ្លងកាត់ផ្លូវថ្នល់។

រាសីឡើងខ្ពស់ត្រដែត។ **ការរកស៊ីៈ** បានកាក់កបល្អណាស់ ព្រោះមានទំនិញលក់ចេញទិញចូលឥតទំនេរដៃ អាចបណ្ដាក់ទុនរកស៊ីដោយទ្រង់ទ្រាយធំបាន។ **ការងារៈ** រាល់ការងារទាំងអស់ទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាព្រមទាំងត្រូវបានបងប្អូនញាតិមិត្តជួយជ្រោមជ្រែងទៀតផង។ **សេដ្ឋកិច្ចៈ** មានផលចំណូលហូរចូលច្រើនពីគ្រប់ទិសទីក្ដី។ តែទ្រព្យច្រើនទុក្ខច្រើនប្រយ័ត្នអាចជួបគ្រោះចោរលួចឆក់ប្លន់។ **សុខភាពៈ** ពិតមែនតែមានសុខភាពល្អជាក្ដី។ តែត្រូវទទួលទានអាហារឱ្យបានទៀងទាត់ពេលវេលាទើបមិនអន្តរាយដល់ក្រពះ។ **ស្នេហាៈ** ចំពោះគូស្នេហ៍មានភាពល្អកល្អិនល្អណាស់។ **គ្រោះថ្នាក់ៈ** ពុំមានអ្វីកត់សម្គាល់ឡើយ។

រាសីស្រុតចុះ។ **ការរកស៊ីៈ** ការរកស៊ីជួបនឹងគូប្រជែងខ្លាំងចេញមុខមកតតាំង។ ដូច្នេះត្រូវត្រៀមលក្ខណៈទុកសម្រាប់ទប់ទល់ជាមុន ទើបមិនបរាជ័យ។ **ការងារៈ** ចំពោះបុគ្គលិកកម្មករនៅតាមបណ្ដាក្រុមហ៊ុន ឬរោងចក្រនានាត្រូវចេះអធ្យាស្រ័យអត់ឱនឱ្យគ្នាទៅវិញទៅមក ទើបពុំមានរឿងជម្លោះវិវាទកើតឡើង។ **សេដ្ឋកិច្ចៈ** មានចំណូលតិចតួច ដូច្នេះកុំរកបានដោយតឹងចាយធូរឱ្យសោះ ប្រយ័ត្នអាចជួបវិបត្តិសេដ្ឋកិច្ចគ្រួសារ។ **សុខភាពៈ** សុខភាពនៅតែមិនល្អជាដដែល។ **ស្នេហាៈ** ចំពោះគូស្នេហ៍មិនត្រូវប្រចែប្រចណ្ឌខុសរឿងឡើយ ទើបពុំមានការប្រេះឆា។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នអាចជួបគ្រោះថ្នាក់ចរាចរណ៍ ក្នុងការបើកបរ។

រាសីល្មមធ្យម។ **ការរកស៊ីៈ** បានកាក់កបល្អគ្រាន់បើ។ ជួញជិតល្អជាងជួញឆ្ងាយ។ **ការងារៈ** រាល់ការងារអ្វីក៏ដោយចូរកុំធ្វេសប្រហែសឱ្យសោះ ជាពិសេសមុនពេលផ្ដិតស្នាមមេដៃ ឬចុះហត្ថលេខាលើលិខិតស្នាមផ្សេងៗ តោងពិនិត្យពិច័យឱ្យបាល្អិតល្អន់។ **សេដ្ឋកិច្ចៈ** នៅដើមខែមានផលចំណូលហូរចូរជាហូរហែរក្ដី។ តែនៅចុងខែខ្សត់ខ្សោយខ្លាំងណាស់។ **សុខភាពៈ** មិនមានចោទបញ្ហាធ្ងន់ធ្ងរក្ដី។ តែត្រូវកាត់បន្ថយគ្រឿងស្រវឹង និងចៀសឱ្យឆ្ងាញពីគ្រឿងញៀន។ **ស្នេហាៈ** ចំពោះគូស្នេហ៍នៅចុងខែអាចជួបរឿងរកាំរកូសច្រើន។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នពេលឡើងចុះជណ្ដើរអាចជួបគ្រោះថ្នាក់ជំពប់ ឬរលិលជើងធ្លាក់។

រាសីឡើងខ្ពស់ត្រដែត។ **ការរកស៊ីៈ** បើមានបងប្អូនញាតិមិត្តស្គាត់មកបបួលរកស៊ីចូលហ៊ុនជាមួយចូរកុំខកខានឱ្យសោះ ព្រោះជាដៃគូរកស៊ីមានចិត្តត្រង់ទៅត្រង់មក។ **ការងារៈ** ចំពោះបុគ្គលិក កម្មករទទួលបានការកោតសរសើរ និងប្រាក់រង្វាន់ពីថៅកែ។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានផលចំណូលហូរចូរច្រើនពីគ្រប់ទិសទីក្ដី។ តែចំពោះទ្រព្យក្ដៅក្រហាយកុំលូកដៃទទួលយកឱ្យសោះ។ **សុខភាពៈ** នៅចុងខែអាចមានជំងឺមាត់ធ្មេញមករំខានខ្លះៗ។ **ស្នេហាៈ** ចំពោះអ្នកនៅលីវ បើចង់ស្វែងរកគូស្រករ គឺនឹងអាចរកបានគូព្រេងពិតៗដូចបំណងប្រាថ្នា។ **គ្រោះថ្នាក់ៈ** ពុំមានជួបគ្រោះថ្នាក់អ្វីធ្ងន់ធ្ងរគួរឱ្យកត់សម្គាល់ឡើយ។

រាសីល្មមធ្យម។ **ការរកស៊ីៈ** ពិតមែនតែងើបឡើងបន្តិចក្ដី។ តែមិនត្រូវប្រកបមុខរបរណាដែលមិនទាន់ស្គាល់ច្បាស់លាស់។ ប្រយ័ត្នអាចវិនាសអន្តរាយទ្រព្យ។ **ការងារៈ** មិនត្រូវរួមការងារជាមួយនឹងមនុស្សសម្ដីផ្អែមឡើយ។ ប្រយ័ត្នអាចធ្លាក់ក្នុងល្បិចកលគេ។ **សេដ្ឋកិច្ចៈ** ពិតមែនតែមានផលចំណូលច្រើនគួរសមក្ដី។ តែទុកមិនគង់ឡើយ ព្រោះរកបានមក ហើយរបូតទៅវិញដោយខ្ទង់ចំណាយធំជាងខ្ទង់ចំណូល។ **សុខភាពៈ** ត្រូវយកចិត្តទុកដាក់របបហូបចុកឱ្យបានទៀងទាត់ពេលវេលា ទើបមិនអន្តរាយដល់សុខភាព។ **ស្នេហាៈ** ត្រូវចេះអត់ឱនឱ្យគ្នាទៅវិញទៅមក ទើបចំណងស្នេហាអាចគង់វង្ស។ **គ្រោះថ្នាក់ៈ** អាចគ្រេចថ្លោះដៃជើង។

រាសីស្រុតចុះ។ **ការរកស៊ីៈ** ច្រើនចាញ់ប្រៀបគេដោយការបង្វិលដើមទុនមានភាពយឺតយ៉ាវ និងខ្វះមុខខ្វះក្រោយ។ ក្រៅពីនោះកុំរកស៊ីល្មើសផ្លូវច្បាប់ឱ្យសោះ។ ប្រយ័ត្នអាចនាំអំពល់ទុក្ខដាក់ខ្លួន។ **ការងារៈ** រាល់កិច្ចការងារជួបបញ្ហាលំបាកៗច្រើន។ ដូច្នេះត្រូវខិតខំពុះពារបន្តិចទើបអ្វីៗអាចដំណើរការបានស្រួលឡើយវិញ។ **សេដ្ឋកិច្ចៈ** មិនត្រូវឱ្យគេខ្ចីលុយកាក់ឬវត្ថុមានតម្លៃឡើយព្រោះកាលបើធ្លាក់ដល់ដៃគេហើយគឺគ្មានថ្ងៃបានវិលវិញឡើយ។ **សុខភាពៈ** នៅចុងខែប្រយ័ត្នអាចមានជំងឺកាចៗមករាតត្បាត។ **ស្នេហាៈ** ត្រូវចៀសវាងការឈ្លោះប្រកែកគ្នា ទើបបានសុខកាយសប្បាយចិត្ត។ **គ្រោះថ្នាក់ៈ** ប្រយ័ត្នការបើកបរពេលយប់ ក្រោយពេលស្រវឹង។

រាសីឡើងខ្ពស់ត្រដែត។ **ការរកស៊ីៈ** អាចបណ្ដាក់ទុនរកស៊ី ឬចេញទៅជួញដូរផ្លូវឆ្ងាយមិនថាផ្លូវគោក ឬផ្លូវទឹកឡើយគឺសមប្រកបទាំងអស់ព្រមទាំងអាចប្រមូលផលចំណេញត្រឡប់ចូលផ្ទះយ៉ាងគាប់ចិត្ត។ **ការងារៈ** ចំពោះអ្នកដែលអត់ការងារធ្វើអាចស្វែងរកការងារល្អៗបានធ្វើសម្រេចដូចបំណងប្រាថ្នា។ **សេដ្ឋកិច្ចៈ** មានចំណូលហូរចូលច្រើនពីគ្រប់ទិសទីអាចបង្កើតដើមទុនរកស៊ីដោយពុំជួបឧបស័គ្គអ្វីមករាំងស្កាត់ឡើយ។ **សុខភាពៈ** មិនត្រូវល្មោភស៊ីល្មោភផឹកឡើយដើម្បីចៀសវាងការអន្តរាយក្រពះពោះវៀន។ **ស្នេហាៈ** និងថ្លើម។ **ស្នេហាៈ** ចំពោះគូរស្នេហ៍ប្រកបតែភាពផ្អែមត្រជាក់ដូចទឹកឃ្មុំ។ **គ្រោះថ្នាក់ៈ** ពុំមានអ្វីឡើយ។

រាសីឡើងខ្ពស់ត្រដែត។ **ការរកស៊ីៈ** អាចបណ្ដាក់ទុនរកស៊ីដោយទ្រង់ទ្រាយតូចធំបាន ហើយបើទោះជាបានជួបគូប្រជែងជើងខ្លាំងចេញមុខមកតតាំងក៏មិនភ័យព្រួយដែរ ព្រោះអាចយកប្រៀបឈ្នះជានិច្ច។ **ការងារៈ** ឱកាសល្អៗមកដល់ហើយ។ ដូច្នេះត្រូវញាប់ដៃញាប់ជើងបន្តិច ព្រោះពេលវេលាជាមាសប្រាក់។ **សេដ្ឋកិច្ចៈ** ជាឱកាសល្អប្រពៃណាស់ក្នុងការប្រមូលទុកដាក់ផលចំណូលឱ្យបានគង់វង្សសម្រាប់ទុកប្រើការនៅពេលមានអាសន្នអន់ក្រ។ **សុខភាពៈ** ត្រូវយកចិត្តទុកដាក់ចំពោះអនាម័យនៃចំណីអាហារ។ **ស្នេហាៈ**មានភាពល្អកល្អិនល្អណាស់។ **គ្រោះថ្នាក់ៈ** អាចដើរជំពប់ជើងដួល។



# មីនា - មេសា



រាសីឡើងខ្ពស់ត្រដែត។ **ការរកស៊ី:** បានកាក់កបល្អណាស់។ អាចបណ្តាក់ទុនរកស៊ីដោយទ្រង់ទ្រាយតូចធំបានពុំមានឧបស័គ្គអ្វីមករាំងស្កាត់ឡើយ។ **ការងារ:** ឱកាសល្អៗបានមកដល់ហើយ ទោះការងារតូចធំត្រូវរៀសរវៃញាប់ជើងញាប់ដៃបន្តិច ព្រោះពេលវេលាជាមាសប្រាក់ធ្វើច្រើនបានច្រើន។ **សេដ្ឋកិច្ច:** ពិតមែនតែមានផលចំណូលហូរចូលច្រើនពីគ្រប់ទិសទីក្តី។ តែដាចខាតកុំឱ្យគេខ្ចីបុល ឬខ្ចីវត្ថុមានតម្លៃឱ្យសោះប្រយ័ត្នអាចចាញ់បោកគេ។ **សុខភាព:** នៅចុងខែអាចមានជំងឺមាត់ធ្មេញមករំខានខ្លះៗ។ **ស្នេហា:** ចំពោះគូស្នេហ៍មានភាពល្អកល្អិននឹងគ្នាល្អណាស់។ **គ្រោះថ្នាក់:** ពុំមានជួបគ្រោះថ្នាក់អ្វីធំដុំគួរឱ្យកត់សម្គាល់ឡើយ។

រាសីស្រុតចុះ។ **ការរកស៊ី:** ជួបគូប្រជែងជើងខ្លាំងចេញមុខមកតតាំង។ ដូច្នេះត្រូវត្រៀមលក្ខណៈទុកសម្រាប់ទប់ទល់ជាមុន ទើបមិនបរាជ័យ។ **ការងារ:** ចំពោះបុគ្គលិកកម្មករនៅតាមបណ្តាក្រុមហ៊ុនឬរោងចក្រនានាតោងចៀសវាងការបង្ករឿងទំនាស់វិវាទជាមួយនឹងថៅកែ ទើបអាចរក្សាតួនាទី និងកន្លែងធ្វើការបានគង់វង្ស។ **សេដ្ឋកិច្ច:** ដោយសាតែផលចំណូលតិចតួចស្តួចស្តើង។ ដូច្នេះកុំរកបានមកដោយតឹងតែចាយធូរឱ្យសោះ។ **សុខភាព:** សុខភាពមិនល្អឡើយ។ **ស្នេហា:** ចំពោះគូស្នេហ៍ប្រយ័ត្នមានជនទី៣ចូលជ្រៀតជ្រែកនាំឱ្យចំណងស្នេហាប្រេះឆា។ **គ្រោះថ្នាក់:** អាចជួបគ្រោះថ្នាក់ពេលដើរឆ្លងកាត់ផ្លូវថ្នល់។

រាសីឡើងខ្ពស់ត្រដែត។ **ការរកស៊ី:** បើមានបងប្អូនញាតិមិត្តមកបបួលរកស៊ីជាមួយចូរកុំខកខានឱ្យសោះ ព្រោះជាដៃគូរកស៊ីដែលមានចិត្តត្រង់ទៅត្រង់មក។ **ការងារ:** ដោយសារតែមានការជួយជ្រោមជ្រែងពីបងប្អូន។ ដូច្នេះទោះបានប្រកបការងារអ្វីក៏ដោយក៏ទទួលបានផលសម្រេចដែល។ **សេដ្ឋកិច្ច:** មានផលចំណូលច្រើនហូរហៀ។ តែទ្រព្យច្រើនទុក្ខច្រើន។ ប្រយ័ត្នអាចជួបគ្រោះចោរលួចឆក់ប្លន់។ **សុខភាព:** នៅចុងខែអាចមានជំងឺឈឺថ្កាត់ខ្លះៗមករាតត្បាត។ **ស្នេហា:** ចំពោះកម្លោះក្រមុំអាចទាក់ទងសាងពន្លកស្នេហាបានដោយគ្មានឧបស័គ្គអ្វីឡើយ។ **គ្រោះថ្នាក់:** ពុំមានអ្វីឡើយ។

រាសីល្អមធ្យម។ **ការរកស៊ី:** ការរកស៊ីជួបការប្រជែងខ្លាំងក្លា។ ដូច្នេះត្រូវចេះសម្របសម្រួលទៅតាមកាលៈទេសៈប្រែប្រួល ទើបអ្វីៗអាចដំណើរការបានស្រួល។ **ការងារ:** សម្ពាធការងារត្រូវបានកាត់បន្ថយជាបណ្តើរៗ។ តែទោះបានប្រកបការងារអ្វីក៏ដោយគឺត្រូវធ្វើទៅតាមគម្រោងផែនការត្រៀមទុក។ **សេដ្ឋកិច្ច:** មានផលចំណូលច្រើនគួរសម។ តែពុំមានសល់អ្វីជាដុំកំភួនឡើយ ព្រោះខ្ទង់ចំណាយធំជាងខ្ទង់ចំណូល។ **សុខភាព:** មិនត្រូវល្មោភស៊ីល្មោភផឹកឡើយ ទើបមិនអន្តរាយដល់ក្រពះពោះវៀន។ **ស្នេហា:** ប្រយ័ត្នមានអ្នកក្រៅនាំរឿងមកអុជអាលនាំឱ្យចំណងស្នេហារង្គោះរង្គើរ។ **គ្រោះថ្នាក់:** រលាកទឹកក្តៅ ឬលង់ទឹក។

រាសីខ្ពស់ត្រដែត។ **ការរកស៊ី:** ការរកស៊ីបានកាត់កបល្អណាស់ ដោយមានទំនិញលក់ចេញទិញចូលឥតទំនេរដៃ ហើយបើទោះជាបានជួបគូប្រជែងជើងខ្លាំងយ៉ាងណាក្តី ក៏មិនត្រូវភ័យព្រួយអ្វីដែរ។ **ការងារ:** ចំពោះអ្នកដែលកំពុងស្វែងរកការងារធ្វើនឹងអាចសម្រេចដូចបំណងប្រាថ្នា។ **សេដ្ឋកិច្ច:** ពិតមែនតែមានផលចំណូលហូរចូលមកពីគ្រប់ទិសទីក្តី។ តែចំពោះទ្រព្យក្តៅក្រហាយ កុំលូកដៃទទួលយកឱ្យសោះ។ **សុខភាព:** មិនមានបញ្ហាចោទទេ តែមិនត្រូវធ្វើការហត់នឿយហួសកម្លាំងឡើយ។ **ស្នេហា:** ចំពោះគូស្នេហ៍ប្រកបតែភាពផ្អែមត្រជាក់ដូចទឹកឃ្មុំ។ **គ្រោះថ្នាក់:** អាចជួបគ្រោះថ្នាក់រអិលឬជំពប់ជើងដួល។

រាសីល្អមធ្យម។ **ការងារ:** ពិតមែនតែងើបឡើងបន្តិចក្តី។ តែនៅតែមានឧបស័គ្គខ្លះៗមករាំងស្កាត់។ ដូច្នេះមិនត្រូវបណ្តាក់ទុនរកស៊ីដោយទ្រង់ទ្រាយធំពេកទេ។ **ការងារ:** ត្រូវចេះធ្វើទំនាក់ទំនងល្អជាមួយនឹងមនុស្សផងទាំងឡាយ ទើបអ្វីៗអាចដំណើរការបានយ៉ាងរលូន។ **សេដ្ឋកិច្ច:** មានផលចំណូលច្រើនគួរសម តែត្រូវកាត់បន្ថយការចាយវាយពុំចាំបាច់ ទើបមិនប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ។ **សុខភាព:** ត្រូវយកចិត្តទុកដាក់ចំពោះអនាម័យនៃចំណីអាហារ។ **ស្នេហា:** ចំពោះគូស្នេហ៍មានភាពស្និទស្នាលដូចប្រក្រតី។ **គ្រោះថ្នាក់:** ប្រយ័តរអិល ឬជពប់ជើងធ្លាក់ពេលឡើងចុះជណ្តើរ។

រាសីល្អមធ្យម។ **ការរកស៊ី:** ជួញជិតល្អជាងជួញឆ្ងាយ ព្រោះការដើរផ្លូវឆ្ងាយបើមិនបានជួបគ្រោះថ្នាក់អាក្រក់ៗទេក៏នឹងបានត្រឹមតែបាតដៃទទេ ត្រឡប់ចូលផ្ទះវិញប៉ុណ្ណោះ។ **ការងារ:** មុនពេលចុះហត្ថលេខា ឬផ្តិតស្នាមមេដៃលើលិខិតស្នាមផ្សេងៗ ត្រូវចេះពិនិត្យពិច័យឱ្យបានល្អិតល្អន់ ទើបពុំមានការថ្លោះធ្លោយ។ **សេដ្ឋកិច្ច:** ពិតមែនតែមានផលចំណូលច្រើនគ្រាន់បើក្តី។ តែពុំមានសល់អ្វីជាដុំកំភួនឡើយ ដោយចាយវាយខ្ជះខ្ជាយពេក។ **សុខភាព:** ត្រូវច្រៀសឱ្យឆ្ងាយពីគ្រឿងស្រវឹង និងគ្រឿងញៀន។ **ស្នេហា:** ចំពោះគូស្នេហ៍ នៅចុងខែអាចជួបរឿងរកាំរកូសច្រើន។ **គ្រោះថ្នាក់:** ប្រយ័តមុតកាំបិតពូថៅ ។

រាសីស្រុតចុះ។ **ការរកស៊ី:** មិនត្រូវហ៊ានប្រថុយប្រថានក្នុងការបណ្តាក់ទុនរកស៊ីដោយទ្រង់ទ្រាយធំឡើយ ហើយក៏មិនត្រូវប្រព្រឹតល្បែងស៊ីសងដែរ។ ប្រយ័ត្នអាចវិនាសអន្តរាយទ្រព្យអស់រលីងពីខ្លួន។ **ការងារ:** មិនត្រូវរួមការងារជាមួយនឹងមនុស្សដែលពុំមានប្រវត្តិច្បាស់លាស់ឡើយ។ ប្រយ័ត្នចាញ់បោកគេ។ **សេដ្ឋកិច្ច:** មិនត្រឹមតែមានផលចំណូលតិចតួចប៉ុណ្ណោះទេព្រមទាំងអាចជួបវិបត្តិសេដ្ឋកិច្ចគ្រួសារទៀតផង។ **សុខភាព:**សុខភាពមិនល្អជាឡើយ។ ត្រូវឆ្លៀតពេលសម្រាកឱ្យបានច្រើន។ **ស្នេហា:** ចំពោះគូស្នេហ៍ជួបរឿងរកាំរកូសចច្រើន។ **គ្រោះថ្នាក់:** ប្រយ័ត្នការបើកបរពេលយប់ និងក្រោយពេលស្រវឹងជោគជាំ។

រាសីឡើងខ្ពស់ត្រដែត។ **ការងារ:** អាចបណ្តាក់ទុនរកស៊ី ឬចេញទៅជួញដូរទីជិតឆ្ងាញ មិនថាផ្លូវគោក ឬផ្លូវទឹកឡើយគឺសមប្រកមតែទាំងអស់។ **ការងារ:** ទោះបានប្រកបការងារអ្វីក៏ដោយក៏អាចទទួលបានផលសម្រេចសមតាមបំណងប្រាថ្នាទាំងអស់ ព្រមទាំងត្រូវបានបងប្អូនញាតិមិត្តជួយឃិតឃោងទៀតផង។ **សេដ្ឋកិច្ច:** ពិតមែនតែមានផលចំណូលហូរចូលច្រើនក្តី។ តែចំពោះទ្រព្យក្តៅក្រហាយកុំលូកដៃទទួលយកឱ្យសោះ។ **សុខភាព:** ចូរកុំល្មោភស៊ីល្មោភផឹកឱ្យសោះ។ ប្រយ័ត្នអាចអន្តរាយដល់ក្រពះពោះវៀន។ **ស្នេហា:** ចំពោះគូស្នេហ៍មានភាពល្អកល្អិនល្អណាស់។ **គ្រោះថ្នាក់:** ពុំមានជួបគ្រោះថ្នាក់អ្វីធំដុំគួរកត់សម្គាល់ឡើយ។

រាសីស្រុតចុះ។ **ការរកស៊ី:** បើមានមនុស្សចម្លែកយករបស់របរមានតម្លៃមកបញ្ចាំ ឬលក់ឱ្យដោយធូរថ្លៃយ៉ាងណាក្តីក៏មិនត្រូវទទួល ឬទិញយកដែរ។ ប្រយ័ត្នអាចជាប់ពាក់ព័ន្ធក្នុងបទល្មើសផ្សេងៗ។ **ការងារ:** ចំពោះបុគ្គលិកកម្មករនៅតាមក្រុមហ៊ុន ឬរោងចក្រនានា ទទួលរកការស្តីបន្ទោសពីថៅកែ។ **សេដ្ឋកិច្ច:** ប្រយ័ត្នអាចជួបគ្រោះចាញ់បោកគេ និងកុំប្រព្រឹត្តល្បែងស៊ីសងឱ្យសោះ។ **សុខភាព:** សុខភាពមិនល្អជាឡើយ។ ត្រូវយកចិត្តទុកដាក់ចំពោះអនាម័យនៃការហូបចុកឱ្យទៀងទាត់ពេលវេលា។ **ស្នេហា:** ចំពោះគូស្នេហ៍ប្រយ័ត្នជនទី៣ចូលជ្រៀតជ្រែក។ **គ្រោះថ្នាក់:** ប្រយ័តរបូតដៃរអិលជើងធ្លាក់ពីទីខ្ពស់។

រាសីល្អមធ្យម។ **ការរកស៊ី:** បើមានមនុស្សសម្តីផ្អែមត្រជាក់បបួលលោកអ្នកឱ្យរកស៊ីចូលហ៊ុនជាមួយចូរកុំទទួលយល់ព្រមឱ្យសោះ ប្រយ័ត្នអាចចាញ់បោកគេ។ **ការងារ:** មិនត្រូវប្រគល់កិច្ចការងារសំខាន់ៗឱ្យគេកាន់កាប់ធ្វើជំនួសឡើយ។ **សេដ្ឋកិច្ច:** ដើមខែមានផលចំណូលច្រើនគួរសម។ តែនៅចុងខែខ្សត់ខ្សោយខ្លាំងណាស់។ ដូច្នេះត្រូវចេះគិតគូរពីការចាយវាយ។ **សុខភាព:** ត្រូវយកចិត្តទុកដាក់ក្នុងការថែមទាំសុខភាពក្រពះពោះវៀន និងថ្លើមឱ្យបានល្អជា។ **ស្នេហា:** ចំពោះគូស្នេហ៍ប្រយ័ត្នមានអ្នកក្រៅនាំរឿងមកអុជអាល។ **គ្រោះថ្នាក់:** ប្រយ័ត្នជួបគ្រោះថ្នាក់ចរាចរពេលយប់។

រាសីស្រុតចុះ។ **ការរកស៊ី:** ច្រើនចាញ់ប្រៀបគេដោយការបង្វិលដើមទុនមានភាពយឺតយ៉ាវ។ ក្រៅពីនោះកុំរកស៊ីតាមផ្លូវងងឹតឱ្យសោះ។ ប្រយ័ត្នអាចជាប់ពាក់ព័ន្ធក្នុងបទល្មើសផ្សេងៗ។ **ការងារ:** រាល់កិច្ចការងារជួបរឿងរកាំរកូសច្រើន។ ដូច្នេះត្រូវចេះអត់ធ្មត់ និងរម្ងាប់ចិត្តឱ្យបានត្រជាក់។ **សេដ្ឋកិច្ច:** ពិតមែនតែមានផលចំណូលតិចតួច។ តែក៏មិនត្រូវមានចិត្តលោភលន់ចង់មានចង់បានឱ្យហួសពេកទេ។ ប្រយ័ត្ននាំអំពល់ទុក្ខដាក់ខ្លួន។ **សុខភាព:** ត្រូវយកចិត្តទុកដាក់ចំពោះអនាម័យចំណីអាហារ។ **ស្នេហា:** មានរឿងរកាំរកូស។ ប្រយ័ត្នចំណងស្នេហាអាចរង្គោះរង្គើរ។ **គ្រោះថ្នាក់:** ប្រយ័ត្នរត់ដួលបែបក្បាល ឬគ្រេចថ្លោះដៃជើង។

# How to visit JAPAN

## ទៅទស្សនានៅជប៉ុន តើយើងគួរស្វែងយល់ចំនុចណាខ្លះ ?

សង្ខេបព័ត៌មានដែលមានប្រយោជន៍សំរាប់ធ្វើដំណើរទៅប្រទេសជប៉ុនគឺតាំងពីព័ត៌មានមូលដ្ឋានមានដូចជាចំនួនប្រជាជន និងផ្ទៃដីអាកាសធាតុ ព្រមទាំងទីកន្លែងទាក់ទាញតាមរដូវកាល និងមធ្យោបាយធ្វើដំណើរក្នុងប្រទេស រហូតដល់របៀបបំពេញបែបបទធ្វើវីសានៅប្រទេសកម្ពុជា។

## ព័ត៌មានមូលដ្ឋានរបស់ប្រទេសជប៉ុន

### ចំនួនប្រជាជន

**126.56 លាន នាក់**

( ខែមករាឆ្នាំ 2018 / ការិយាល័យស្ថិតិនៃក្រសួងកិច្ចការផ្ទៃក្នុង និងគមនាគមន៍ )

ប្រទេសកម្ពុជាមានប្រមាណ 15.56លាននាក់

( ការិយាល័យស្ថិតិនៃក្រសួងផែនការ )

### ផ្ទៃដី

**378,000 km²**

ប្រមាណពីរដងនៃប្រទេសកម្ពុជា ( កម្ពុជា: 181,035 km² )

### ម៉ោងនៅជប៉ុន

**ម៉ោងកម្ពុជា +2 ម៉ោង**

ពេលម៉ោង12ថ្ងៃត្រង់នៅប្រទេសកម្ពុជា គឺត្រូវនឹងម៉ោង2 រសៀលនៅប្រទេសជប៉ុន

### ភាសា

**ភាសាជប៉ុន** ( ជាភាសាផ្លូវការជាក់ស្តែង )

ប្រជាជនជប៉ុនភាគច្រើនមិនអាចនិយាយភាសាអង់គ្លេសបាន ដូច្នេះវាមានការពិបាកបន្តិចចំពោះភ្ញៀវទេសចរណ៍។ មានកន្លែងជាច្រើនដែលសរសេរការណែនាំជាភាសាអង់គ្លេសដូចជានៅតាមស្ថានីយ៍ជាដើម ប៉ុន្តែក៏មានផ្លាកសញ្ញានៃអគារនិងផ្លូវមួយចំនួនសរសេរតែភាសាជប៉ុនដែរ។ វាមានភាពងាយស្រួលបើរៀបចំទុកនូវកម្មវិធីណែនាំនៅក្នុងទូរស័ព្ទស្មាតហ្វូន ឬផែនទីដែលសរសេរជាភាសាអង់គ្លេស។

### រូបិយប័ណ្ណ

**US$1** ( ប្រហែល ៤០០០រៀល )

**= ប្រហែល 110 យ៉េន**

* អត្រាប្តូរប្រាក់ប្រែប្រួលជារៀងរាល់ថ្ងៃ។

នៅប្រទេសជប៉ុនមានក្រដាសប្រាក់ចាប់ពី 1,000យ៉េនឡើងទៅ ហើយតម្លៃតូចជាងនេះគឺជាកាក់។

**● លុយធីប**

នៅប្រទេសជប៉ុនមិនមានទំលាប់ឱ្យលុយធីបទេ។

### ពន្ធ

**ពន្ធលើការប្រើប្រាស់ 8%**

ចាប់ពីឆ្នាំ2018 នេះជាគោលការណ៍តម្លៃដែលបង្ហាញលើទំនិញគឺតម្លៃពន្ធត្រូវបានរួមបញ្ចូលជាស្រេច។

**● ហាងទំនិញដែលលើកលែងពន្ធ**

នៅហាងទំនិញដែលលើកលែងពន្ធប្រើប្រាស់ 8% ត្រូវបានលើកលែង។ គិតត្រឹមខែតុលាឆ្នាំ 2017 មានប្រហែល 43,000 ហាងនៅទូទាំងប្រទេសដែលផ្តោតសំខាន់លើហាងលក់គ្រឿងអេឡិចត្រូនិច ហាងលក់ថ្នាំ ហាងលក់សំភារៈផ្សេងៗ។ល។ គេត្រូវការលិខិតឆ្លងដែន ( ច្បាប់ដើម ) ដែលមានបង្ហាញត្រាសុំទិដ្ឋិការគឺជាកាចាំបាច់។

**▼ យោងតាម**

**● Website「JAPAN. Tax-Free Shop」**

https://tax-freeshop.jnto.go.jp/eng/index.php

បន្ថែមលើព័ត៌មានការស្វែងរកហាងទំនិញដែលលើកលែងពន្ធ និងរបៀបកាត់ពន្ធក៏មានការណែនាំកន្លែងទេស_ចរណ៍តាមតំបន់នីមួយៗក្នុងប្រទេសជប៉ុនផងដែរ។

# ការពិសាស្រា·ការជក់បារី

នៅក្នុងប្រទេសជប៉ុនការផឹកស្រានិងជក់បារីក្រោមអាយុ20ឆ្នាំត្រូវបានហាមឃាត់ដោយច្បាប់។ ជនបរទេសដែលស្នាក់នៅប្រទេសជប៉ុនត្រូវគោរពតាមច្បាប់របស់ជប៉ុន ដូច្នេះត្រូវប្រុងប្រយ័ត្ន! នៅភោជនីយដ្ឋានដែលលក់ស្រា និងហាងលក់បារីគឺត្រូវមានកាតបង្ហាញអត្តសញ្ញាណប័ណ្ណដែលអាចផ្ទៀងផ្ទាត់អាយុបាន។

## ● កន្លែងជក់បារី

ការជក់បារីនៅតាមដងផ្លូវគឺត្រូវបានហាមឃាត់ដោយបទបញ្ញត្តិនៃក្រុងខ័ណ្ឌឃុំភូមិជាច្រើនកន្លែង ប្រសិនបើអ្នកជក់បារីនៅ ក្រៅកន្លែងដែលកំណត់ គឺត្រូវបង់លុយពិន័យ ដូច្នេះត្រូវប្រយ័ត្ន។ ភាគច្រើននៅតាមហាងកាហ្វេ និងភោជនីយដ្ឋានជាដើមគឺត្រូវបានបែងចែកផ្នែកកន្លែងមិនជក់បារី និងផ្នែកកន្លែងជក់បារី។

# តង់ស្យុងអគ្គិសនី

តង់ស្យុងអគ្គិសនីរបស់ប្រទេសជប៉ុនគឺ 100V ប្រេកង់នៅភាគខាងកើតប្រទេសជប៉ុនគឺ 50Hz សម្រាប់នៅភាគខាងលិចប្រទេសជប៉ុនគឺ 60Hz។ ពេលប្រើប្រាស់គ្រឿងអគ្គិសនីតង់ស្យុង 200V នៃប្រទេសកម្ពុជាក្នុងប្រទេសជប៉ុនគឺចាំបាច់ត្រូវប្រើប្រដាប់ផ្លាស់ប្តូរតង់ស្យុងអគ្គិសនី។ អាដាប់ទ័រថាមពលភាគច្រើនសម្រាប់សាកកុំព្យូទ័រផ្ទាល់ខ្លួន និងទូរស័ព្ទថ្មីៗនេះអាចប្រើប្រាស់បានទូទាំងពិភពលោក ដូច្នេះរបស់ភាគច្រើនអាចប្រើប្រាស់បាន (INPUT:100-240V 50-60Hz)។ នៅក្នុងប្រទេសជប៉ុនរូបរាងនៃប្រីភ្លើងគឺជាប្រភេទមានរន្ធដោតពីររាងតំប៉ែតប្រភេទA។ សូមប្រុងប្រយ័ត្នចំពោះឧបករណ៍ដែលមានឌុយដោតភ្លើងខុសគ្នា (ប្រភេទមូល ប្រភេទមានជើងបីជាដើម។ល។) គឺអ្នកត្រូវការអាដាប់ទ័រដើម្បីដោតវា។

※ ប្រដាប់ផ្លាស់ប្តូរតង់ស្យុងអគ្គិសនី និងអាដាប់ទ័រដោតគឺអាចទិញបាននៅតាមហាងអគ្គិសនីធំៗក្នុងប្រទេសជប៉ុន។



A type　SE type　BF type

# ការទំនាក់ទំនង

## ● ការប្រើប្រាស់ទូរស័ព្ទដៃ

នៅក្នុងប្រទេសជប៉ុនការប្រើប្រាស់ទូរស័ព្ទដៃគឺត្រូវចុះកិច្ចសន្យាជាមួយក្រុមហ៊ុនទូរគមនាគមន៍ហើយបង់ថ្លៃសេវាប្រចាំខែរួមទាំងការនិយាយទូរស័ព្ទ និងសេវាអ៊ីនធើណេត។ បើប្រៀបធៀបដូចនឹងប្រទេសកម្ពុជាដែលទិញSIMកាតរបស់ក្រុមហ៊ុនទូរគម_នាគមន៍គឺមានភាពស្មុគស្មាញបន្តិច ប៉ុន្តែនៅតាមព្រលានយន្ត_ហោះជប៉ុនមានលក់SIMកាតសម្រាប់ភ្ញៀវទេសចរណ៍បរទេស។

## ● កន្លែង WiFi ឥតបង់លុយ

ប្រព័ន្ធអ៊ីនធើណេត WiFi ដែលឥតគិតថ្លៃក៏កំពុងតែកើនឡើងផងដែរនៅតាមភោជនីយដ្ឋាន និងស្ថានីយ៍រថភ្លើងជាដើម ប៉ុន្តែដើម្បីប្រើប្រាស់គេតម្រូវឱ្យធ្វើការចុះឈ្មោះជាមុនសិន ដូច្នេះត្រូវប្រុងប្រយ័ត្ន។ ថ្មីៗនេះប្រសិនបើអ្នកទាញយកកម្មវិធីទុកជាមុន អ្នកអាចប្រើប្រាស់សេវាកម្មប្រព័ន្ធអ៊ីនធើណេត WiFi ឥតគិតថ្លៃនៅកន្លែងផ្សេងៗជាច្រើន។

Wi Fi FREE

▼ យោងតាម

● **Website「JAPAN Mobile Tips」**
www.jnto.go.jp/mobiletips/eng/

គេហទំព័រដែលសង្ខេបព័ត៌មានការប្រើប្រាស់ទូរស័ព្ទចល័តនៅក្នុងប្រទេសជប៉ុន។ SIM កាត រូតទ័រ WiFi ការប្រើប្រាស់WiFiឥតគិតថ្លៃជាដើម។

● **「Japan Connected-free Wi-Fi 」**
● **「Travel Japan Wi-Fi 」**

ប្រសិនបើអ្នកទាញយកកម្មវិធីទាំងពីរខាងលើទុកជាមុន អ្នកអាចប្រើប្រាស់សេវាកម្ម WiFi ឥតគិតថ្លៃនៅកន្លែងដែលមាន WiFi។

# ថ្ងៃឈប់សម្រាក

ថ្ងៃឈប់សម្រាកសម្រាប់ឆ្នាំ2018មានដូចខាងក្រោម។ នៅពេលថ្ងៃឈប់សម្រាកត្រួតគ្នាចំថ្ងៃអាទិត្យគឺត្រូវផ្ទេរទៅឈប់នៅថ្ងៃច័ន្ទបន្តទៀតវិញ។ នៅប្រទេសជប៉ុនគេធ្វើដំណើរកំសាន្តនៅថ្ងៃចុងសប្តាហ៍ នៅមុនថ្ងៃបុណ្យមួយថ្ងៃ~ថ្ងៃបុណ្យ វិស្សមកាលបុណ្យ OBON (ថ្ងៃទី13ដល់ថ្ងៃទី16ខែសីហា) បុណ្យចូលឆ្នាំថ្មី (ថ្ងៃទី29ខែ12ឆ្នាំ2018~ថ្ងៃទី3ខែ1ឆ្នាំ2019) គឺធ្វើឱ្យចរាចរណ៍មានភាពមមាញឹកនិងតម្លៃសណ្ឋាគាឡើងថ្លៃទៀតដូច្នេះសូមប្រុងប្រយ័ត្ន។

| | | | | | |
|---|---|---|---|---|---|
| ខែមករា | ថ្ងៃទី01 | ចូលឆ្នាំថ្មី | ខែកក្កដា | ថ្ងៃទី16 | ថ្ងៃបុណ្យសមុទ្រ |
| | ថ្ងៃទី08 | ថ្ងៃពេញវ័យ | ខែសីហា | ថ្ងៃទី11 | ថ្ងៃបុណ្យភ្នំ |
| ខែកុម្ភៈ | ថ្ងៃទី11 | ថ្ងៃបង្កើតប្រទេស | ខែកញ្ញា | ថ្ងៃទី17 | ថ្ងៃរំលឹកគុណមនុស្សចាស់ |
| | ថ្ងៃទី12 | ថ្ងៃឈប់សម្រាកដែលផ្ទេរ | | ថ្ងៃទី23 | ថ្ងៃចូលសរទះរដូវ |
| ខែមីនា | ថ្ងៃទី21 | ថ្ងៃនិទាឃរដូវ | | ថ្ងៃទី24 | ថ្ងៃឈប់សម្រាកដែលផ្ទេរ |
| ខែមេសា | ថ្ងៃទី29 | ថ្ងៃShowa | ខែតុលា | ថ្ងៃទី08 | ទិវាសុខភាពនិងកីឡា |
| | ថ្ងៃទី30 | ថ្ងៃឈប់សម្រាកដែលផ្ទេរ | ខែវិច្ឆិកា | ថ្ងៃទី03 | ទិវាវប្បធម៌ |
| ខែឧសភា | ថ្ងៃទី03 | ទិវារំលឹករដ្ឋធម្មនុញ្ញ | | ថ្ងៃទី23 | ថ្ងៃអំណរគុណការធ្វើការងារ |
| | ថ្ងៃទី04 | ថ្ងៃបៃតង | ខែធ្នូ | ថ្ងៃទី23 | ថ្ងៃចំរើនព្រះជន្មព្រះចៅអធិរាជ |
| | ថ្ងៃទី05 | ថ្ងៃបុណ្យកុមារ | | ថ្ងៃទី24 | ថ្ងៃឈប់សម្រាកដែលផ្ទេរ |

# អាកាសធាតុនិងរដូវ

## អាកាសធាតុ

តំបន់ភាគច្រើននៃប្រទេសជប៉ុនស្ថិតនៅតំបន់កក់ក្តៅដែលមានសីតុណ្ហភាពខុសគ្នាក្នុងបួនរដូវ ហើយអាកាសធាតុក្នុងរដូវក្តៅ និងរដូវរងាគឺខុសគ្នាខ្លាំង។ ម្យ៉ាងទៀតសណ្ឋានដីជប៉ុនមានរៀងវែងពីភាគខាងត្បូងទៅខាងជើងហើយទទួលឥទ្ធិផលពីខ្យល់រដូវកាល និងចរន្តទឹកសមុទ្រដែលនាំអោយអាកាសធាតុតាមតំបន់នីមួយៗមានភាពខុសៗគ្នា។ ហុកកៃដូដែលស្ថិតនៅភាគខាងជើងបង្អស់នៃប្រទេសគឺ មានភាពត្រជាក់ខ្លាំងក្នុងរដូវរងា។ Okinawa ដែលស្ថិតនៅភាគខាងត្បូងបង្អស់នៃប្រទេស បើប្រៀបធៀបទៅវាមានសីតុណ្ហភាពក្តៅពេញមួយឆ្នាំទោះបីជារដូវរងាក៏មិនរងាខ្លាំងដែរ (បើប្រៀបធៀបជាមួយប្រទេសកម្ពុជាគឺ វាពិតត្រជាក់ជាង)។

លើសពីនេះទៀត ដោយសារតែជប៉ុនមានជួរភ្នំខ្ពស់ៗគ្នា ធ្វើឱ្យរដូវរងារមានពពកឬព្រិល និងភ្លៀងជាញឹកញាប់នៅក្នុងផ្នែកនៃសមុទ្រជប៉ុន ប៉ុន្តែផ្នែកខាងមហាសមុទ្រប៉ាស៊ីហ្វិកវិញគឺភាគច្រើនមេឃស្រលះ។

### រដូវភ្លៀង

ជាទូទៅចាប់ពីចុងខែមិថុនាដល់ចុងខែកក្កដា មានភ្លៀងធ្លាក់ច្រើនលើកលែងតែ Hokkaido។ វាមិនមែនជាភ្លៀងធ្លាក់ខ្លាំងៗទេ តែវារលឹមស្រិចៗ។ នៅក្នុងរដូវនេះ សីតុណ្ហភាពធ្លាក់ធ្វើឱ្យត្រជាក់។

### ខ្យល់ព្យុះ

ព្យុះស៊ីក្លូនត្រូពិចកើតនៅលើសមុទ្រភាគខាងត្បូងគឺ បក់ឆ្លងកាត់ប្រទេសជប៉ុនជាច្រើនដងពីខែកក្កដាដល់ខែតុលា។ វានាំមកជាមួយខ្យល់បក់ និងភ្លៀងយ៉ាងខ្លាំង ពេលបក់ឆ្ពោះទៅភាគខាងជើង ដូច្នេះបណ្តាលអោយមានគ្រោះមហន្តរាយដូចជាបាក់ភ្នំ នីវ៉ូទឹកសមុទ្រឡើងខ្ពស់ ទឹកជំនន់ជាដើម។

## រដូវ

រដូវរបស់ប្រទេសជប៉ុនបែងចែកជា៤គឺរដូវផ្ការីក រដូវក្តៅ រដូវស្លឹកឈើជ្រុះនិងរដូវរងារ ដែលយើងអាចសប្បាយជាមួយទេសភាពក្នុងរដូវទាំង៤ ពិធីបុណ្យ ចំណីអាហារជាដើម។

### រដូវផ្ការីក



រដូវរងារផុតឈានចូលរដូវក្តៅ ផ្កា SAKURA ជាចំបងគេ និងមានផ្កាផ្សេងៗទៀតជាច្រើនរីក ដែលជារដូវធ្វើឱ្យមានអារម្មណ៍ស្រស់ស្រាយ។ បើទោះបីជាយ៉ាងនេះក៏ដោយ ផ្កា SAKURA រីកចាប់ពីចុងខែមីនាទៅខែដើមខែមេសា ហើយអ្នកមកពីប្រទេសកម្ពុជានៅតែមានអារម្មណ៍ត្រជាក់នៅឡើយ ដូច្នេះ អ្នកទៅក្នុងរដូវនេះគួរការពារកុំអោយត្រជាក់។



● កន្លែងទស្សនា･ព្រឹត្តិការណ៍

**SAKURA, ការមើលផ្កាជាដើម**

បើនិយាយពីរដូវផ្ការីក គេសំដៅលើផ្កា SAKURA។ ភ្ញៀវទេសចរណ៍បរទេសជាច្រើនក៏បានមកទស្សនាផ្កា SAKURA។ ប៉ុន្តែផ្កា SAKURA រីកអាស្រ័យលើអាកាសធាតុនៃឆ្នាំនីមួយៗ និងតាមតំបន់នីមួយៗ ដូច្នេះសូមប្រុងប្រយ័ត្ន។ គួរស្វែរកពត៍មានលើបណ្តាញអ៊ីនធើណេតជាដើម។ ផ្កា SAKURA រីកចាប់ពីភាគខាងត្បូងនៃប្រទេស ហើយរៀងរាល់ឆ្នាំនៅចុងខែមីនា~ដើមខែមេសាគឺផ្កា SAKURA នៅតូក្យូរីកស្រស់ស្អាតគួរឱ្យគយគន់។

### រដូវក្តៅ



វាជារដូវដែលព្រះអាទិត្យបញ្ចេញពន្លឺកំដៅ។ ពេលរដូវភ្លៀងនៅចុងខែមិថុនាដល់ពាក់កណ្តាលខែកក្កដាកន្លងផុតទៅភ្លាមនោះសីតុណ្ហភាពកើនយ៉ាងលឿននេះបញ្ជាក់ថារដូវក្តៅមកដល់ហើយ។ សីតុណ្ហភាពខ្ពស់បំផុតកើនជិតដល់៤០អង្សារអាស្រ័យលើថ្ងៃ និងទីកន្លែងរដូវក្តៅនៅប្រទេសជប៉ុនមានសំណើមខ្ពស់ ដូច្នេះថ្ងៃខ្លះអាចមានអារម្មណ៍ថាក្តៅជាងប្រទេសកម្ពុជាទៅទៀត។



● កន្លែងទស្សនា･ព្រឹត្តិការណ៍

**បុណ្យរដូវក្តៅ, កម្មវិធីបាញ់កាំជ្រួច ឡើងភ្នំហ្វូជី, ហែលទឹកសមុទ្រ ជាដើម**

នៅប្រទេសជប៉ុនមានវិស្សមកាលរដូវក្តៅក្នុងរដូវនេះ ហើយមានព្រឹត្តិការណ៍ជាច្រើនដូចជាកម្មវិធីបុណ្យជាដើម។ ជាពិសេសកម្មវិធីបាញ់កាំជ្រួចគឺជាប្រពៃណីនៃរដូវក្តៅ។ វាត្រូវបានប្រារព្វធ្វើឡើងតាមតំបន់នីមួយៗទូទាំងប្រទេស ហើយកាំជ្រួចរាប់ពាន់ទៅរាប់ម៉ឺនគ្រាប់នឹងត្រូវបាញ់បង្ហោះទៅលើមេឃដែលគួរឱ្យទស្សនា សូមមកទស្សនាឱ្យបានម្តង។

## ● សីតុណ្ហភាព និងបរិមាណភ្លៀងប្រចាំឆ្នាំ ( ជប៉ុន / កម្ពុជា )

សីតុណ្ហភាពជាមធ្យម — Tokyo — ភ្នំពេញ

កំពស់ទឹក — Tokyo — ភ្នំពេញ




# រដូវស្លឹកឈើជ្រុះ



កំដៅក៏បានធ្លាក់ចុះ ហើយសំណើមក៏បានធ្លាក់ចុះដែលជារដូវមានភាពងាយស្រួល។ ក្រៅពីស្លឹកឈើជ្រុះដែលមានប្រជាប្រិយភាពសំរាប់ជនបរទេស រដូវស្លឹកឈើជ្រុះក៏ជារដូវដែលមានចំណីអាហារឆ្ងាញ់ៗផងដែរ។ បើអញ្ជើញមកលេងក្នុងរដូវនេះ សូមអញ្ជើញសាកល្បងម្ហូបអាហារក្នុងរដូវកាលនេះផង។



### ● កន្លែងទស្សនា・ព្រឹត្តិការណ៍

**ស្លឹកឈើពណ៌ក្រហម,**

**ផ្កា Cosmos, រសជាតិនៃរដូវស្លឹកឈើជ្រុះ ជាដើម**

ពណ៌ស្លឹកឈើតាមដើមឈើលើភ្នំ និងដើមឈើតាមផ្លូវ បានផ្លាស់ពីពណ៌បៃតងទៅជាពណ៌ក្រហមឬក៏ពណ៌លឿងជាដើមគឺពិតជាស្រស់ស្អាត អាចនិយាយបានថាសម្រស់សិល្បៈធម្មជាតិ! ដោយសារតែហេតុនេះហើយទើបរដូវស្លឹកឈើជ្រុះក៏ដូចរដូវផ្ការីកនៃផ្កា SAKURA នៅ Kyoto, Nara, Nikko ជាដើមគឺជាចំណុចដែលមានភ្ញៀវទេសចរណ៍ជាច្រើនមកប្រមូលផ្តុំដើម្បីរើសស្លឹកក្រហម។

# រដូវរងា



វាជារដូវត្រជាក់បំផុតនៃឆ្នាំ។ បើអ្នកទៅកំសាន្តប្រទេសជប៉ុនក្នុងរដូវនេះគឺសូមរៀបចំសម្លៀកបំពាក់សំរាប់រដូវរងារផង។ បើទោះបីជាវាត្រជាក់ខ្លាំងបន្តិច ប៉ុន្តែទេសភាពព្រិលដែលគ្មានក្នុងប្រទេសកម្ពុជាគឺគួរតែទៅមើលដោយផ្ទាល់ភ្នែកម្តង។



### ● កន្លែងទស្សនា・ព្រឹត្តិការណ៍

**ព្រិល, ស្គី (កីឡារដូវត្រជាក់),**

**ពិធីបុណ្យចូលឆ្នាំថ្មី ជាដើម**

ទោះជាយ៉ាងណាក៏ដោយវាមិនមានព្រិលធ្លាក់គរនៅគ្រប់កន្លែងទូទាំងប្រទេសនោះក្នុងរដូវរងារទេ។ កន្លែងពេញនិយមសំរាប់ភ្ញៀវទេសចរណ៍ដែលចង់ប៉ះព្រិលគឺ មានរមណីយដ្ឋានជិះស្គីពេញនិយមស្ថិតនៅ Hokkaido និងខេត្ត Nagano អ្នកអាចសប្បាយរីករាយជាមួយនឹងអុងសេន( ទឹកក្តៅ )នៅ Zao ខេត្ត Yamagata ទេសភាពព្រិលនៅ Shirakawago នៃខេត្ត Gifu ជាកន្លែងមានផ្ទះបែបប្រពៃណីបុរាណចាស់ដែលត្រូវបានចុះបញ្ជីបេតិកភណ្ឌពិភពលោក។

# រៀបចំដើម្បីទៅដើរលេង

## VISA ការណែនាំដើម្បីទទួលបានវីសា

ប្រជាជនកម្ពុជាមានបំណងចង់ទៅប្រទេសជប៉ុនអាចដាក់ពាក្យស្នើសុំទិដ្ឋាការនៅស្ថានទូតជប៉ុននៅភ្នំពេញ។ ព័ត៌មានខាងក្រោមគឺជាការណែនាំត្រួសៗអំពីការដាក់ពាក្យស្នើសុំទិដ្ឋាការស្នាក់នៅរយៈពេលខ្លី(សម្រាប់ការស្នាក់នៅរយៈពេល៩០ថ្ងៃ ឬតិចជាងនេះ ដោយមិនរាប់បញ្ចូលសកម្មភាពដែលទទួលបានប្រាក់កម្រៃ)។

*សម្រាប់ព័ត៌មានលម្អិតសូមទាក់ទងសួរនៅស្ថានទូតជប៉ុន។

### ● តើអ្នកអាចទទួលបានទិដ្ឋាការនៅឯណា?

**ស្ថានទូតជប៉ុននៅកម្ពុជា**

www.kh.emb-japan.go.jp/itprtop_en/index.html

**Add: No.194, Moha Vithei Preah Norodom, Sangkat Tonle Bassac, Khan Chamkar Mon, Phnom Penh, Cambodia**
**Tel: 023-217161~4**

ម៉ោងធ្វើការសំរាប់ស្នើសុំទិដ្ឋាការ៖
(ផ្នែកកុងស៊ុល៖ ទទួលពាក្យសុំនិងពិនិត្យលើឯកសារ)

ម៉ោងទទួលពាក្យសុំ / ដាក់ពាក្យសុំទិដ្ឋាការ៖
ថ្ងៃច័ន្ទ-ថ្ងៃសុក្រ ពីម៉ោង ៨:០០ - ១២:០០

ម៉ោងមកទទួលលទ្ធផលទិដ្ឋាការ៖
ថ្ងៃច័ន្ទ-ថ្ងៃសុក្រ ពីម៉ោង ១៤:០០ - ១៦:៣០

**about visa**:
www.kh.emb-japan.go.jp/consular/visa/visa-index-e.htm

### ● តើត្រូវការរយៈពេលប៉ុន្មានដើម្បីទទួលបានទិដ្ឋាការ?

អ្នកដាក់ស្នើនឹងទទួលបានលទ្ធផលទិដ្ឋាការក្នុងរយៈពេល៥ថ្ងៃ រាប់ទាំងថ្ងៃដាក់ពាក្យសុំ ប៉ុន្តែការពិនិត្យលើពាក្យស្នើសុំអាចមានការខុសៗពីគ្នាអាស្រ័យលើឯកសារ។ លើសពីនេះ ការទទួលបានលទ្ធផលទិដ្ឋាការអាចត្រូវការពេលវេលាច្រើនជាងនេះ ពេលមានការកើនឡើងនៃចំនួនអ្នកដាក់ពាក្យស្នើសុំ។ ហេតុនេះអ្នកដាក់ពាក្យសុំគួរតែលៃពេលដាក់ពាក្យសុំទិដ្ឋាការទុកជាមុនអោយបានយូរ មិនគួរដាក់ពាក្យសុំទិដ្ឋាការកៀកថ្ងៃចេញដំណើរពេកទេ។

### ● តើការទទួលបានទិដ្ឋាការត្រូវអស់តម្លៃប៉ុន្មាន?

ទិដ្ឋាការចូលតែមួយដង: ១១០ ០០០រៀល
ទិដ្ឋាការចូលច្រើនដង: ២២០ ០០០រៀល
ទិដ្ឋាការឆ្លងកាត់: ២៥ ០០០រៀល

### ● តើអ្នកត្រូវការអ្វីខ្លះដើម្បីដាក់ពាក្យសុំទិដ្ឋាការ?

1. លិខិតឆ្លងដែន
2. ពាក្យស្នើសុំទិដ្ឋាការ
3. រូបថត (4.5cm x 4.5cm) មួយសន្លឹក
4. លិខិតបញ្ជាក់ការងារ
5. ឯកសារដើម្បីបង្ហាញពីសមត្ថភាពក្នុងការចំណាយសម្រាប់ថ្លៃធ្វើដំណើរ
6. គម្រោងកម្មវិធីស្នាក់នៅ
7. សៀវភៅគ្រួសារ

**ព័ត៌មានលំអិតអំពីឯកសារ** (ជាភាសាខ្មែរ)
www.kh.emb-japan.go.jp/consular/visa/visa-documents-k20170704.pdf

## យន្តហោះទៅប្រទេសជប៉ុន

មានជើងហោះហើរជាច្រើនពីកម្ពុជាទៅជប៉ុន។ ខាងក្រោមនេះយើងនឹងណែនាំពីការហោះហើររបស់អ្នកតំណាង។

### ● ជើងហោះហើរផ្ទាល់

បច្ចុប្បន្នមានតែ ANA តែប៉ុណ្ណោះដែលមានជើងហោះហើរដោយផ្ទាល់រវាងប្រទេសកម្ពុជា និងជប៉ុន។ ពេលហោះហើរគឺប្រហែល 6 ម៉ោង។

**All Nippon Airway (ANA)**
Phnom Penh – Narita 22:50-06:30
Narita – Phnom Penh 10:50-15:40

*ពេលវេលាអាចផ្លាស់ប្តូរ

### ● ជើងហោះហើរប្រយោល

មានជើងហោះហើរជាច្រើនទៅប្រទេសជប៉ុន។ ប្រទេសដទៃទៀតពេលវេលាហោះហើរពីម៉ោងប្រហែល 8 ម៉ោងចូរពិនិត្យមើលកាលវិភាគជើងហោះហើរនៅលើគេហទំព័រក្រុមហ៊ុនអាកាសចរណ៍នីមួយៗកន្លែងស្វែងរកសំបុត្រនៅកន្លែងធ្វើដំណើរជាដើម។

- តាមរយៈ គូឡាឡាំពួ (ម៉ាឡេស៊ី)
- តាមរយៈ បាងកក (ថៃ)
- តាមរយៈ ហាណូយ / ហូជីមិញ (វៀតណាម)
- តាមរយៈ សិង្ហបុរី
- តាមរយៈ សៀងហៃ / ក្វាងចូវ (ប្រទេសចិន)
- តាមរយៈ ហុងកុង
- តាមរយៈ តៃវ៉ាន ។ល។


រូបភាព
4 ប្រភេទ
Preah Ream
ព្រះរាម
Hanumam
ហនុមាណ
Sokrip & Pealy
សុគ្រីប និង ពាលី
Reach Roth
រាជរថ



NyoNyum Original
The ReamKer Post Card
1set រឿងរាមកេរ្តិ៍
4 post cards
$3
អាចទិញវាបាននៅ
NyoNyum Shop
ថ្ងៃចន្ទ-ថ្ងៃសៅរ៍ 9:00-17:30
Tel: 023-726-214
#4, St.432 (corner St.95), Phnom Penh

# មធ្យោបាយធ្វើដំណើរនៅប្រទេសជប៉ុន

មធ្យោបាយសំខាន់នៃការធ្វើដំណើរនៅក្នុងប្រទេសជប៉ុនមានដូចខាងក្រោម

## យន្តហោះ

មានអាកាសយានដ្ឋាននៅតាមខេត្តជាច្រើននៅទូទាំងប្រទេសជប៉ុន ជាពិសេសពីទីក្រុងធំៗ ដូចជា Tokyo និង Osaka មានជើងហោះហើរជាច្រើនត្រូវបានបើកទៅកន្លែងផ្សេងៗជារៀងរាល់ថ្ងៃ។ ថ្មីៗនេះក្រៅពីក្រុមហ៊ុនអាកាសចរណ៍ធំ ៗ ANA និង JAL ដូចជា Jetstar, AirAsia, peach និង Vanilla វាបានបង្កើនចំនួនក្រុមហ៊ុនអាកាសចរណ៍ដែលមានតម្លៃទាប (LCC)។

## រថភ្លើងល្បឿនលឿន "Shinkansen"

ទីក្រុងធំៗ និងជនបទត្រូវបានតភ្ជាប់ដោយរថភ្លើងល្បឿនលឿន "Shinkansen"។ សំបុត្ររថភ្លើងជប៉ុន "Japan Rail Pass" ដែលជាសំបុត្រដ៏អស្ចារ្យសម្រាប់ភ្ញៀវបរទេសដែលមកទស្សនាប្រទេសជប៉ុន អ្នកអាចទិញសំបុត្របានដោយយោងទៅតាមចំនួនថ្ងៃ និងកៅអី ហើយផ្លូវដែក JR មានជាច្រើន (ផ្លូវរថភ្លើងល្បឿនលឿន) និងខ្សែរថភ្លើងនៅទូទាំងប្រទេសជប៉ុនទទួលបានដោយឥតគិតថ្លៃ ដើម្បីចូល ឬចេញវាមានភាពងាយស្រួលក្នុងការធ្វើដំណើរតាមផ្លូវដែកឆ្លងកាត់ជុំវិញប្រទេសជប៉ុនជាមួយ និងតំលៃសមរម្យ។

**សំរាប់ព័ត៌មានលំអិតអំពី "Japan Rail Pass"**
japanrailpass.net/en/about_jrp.html

## ផ្លូវហាយវេសម្រាប់រថយន្ត / ផ្លូវរថយន្តក្រុងក្នុងទីក្រុង

ផ្លូវដែលបានប្រើប្រាស់ដោយឡានក្រុងតភ្ជាប់ទូទាំងប្រទេសជប៉ុន។ យើងអាចធ្វើដំណើរបានឆ្ងាយច្រើនហើយធូរថ្លៃជាងបើប្រៀបធៀបទៅនឹងយន្តហោះ និងរថភ្លើង Shinkansen។ ដូចគ្នានេះផងដែរមានឡានក្រុងដឹកជញ្ជូនមានកំណត់នៅគ្រប់ក្រុង និងទីប្រជុំជនក្នុងប្រទេសងាយស្រួលក្នុងការផ្លាស់ទីកន្លែងដែលរថភ្លើងមិនឆ្លងកាត់។

## នាវា

ក្រៅពីនាវាដឹកជញ្ជូនក្នុងស្រុកដូចជាខ្សែតភ្ជាប់កំពង់ផែនៃកោះសំខាន់ៗ និងកោះដូចជា Okinawa ជាដើម ផ្លូវអន្តរជាតិ (ដូចជាកូរ៉េជាដើម។ល។) ក៏បានមកពីកំពង់ផែមួយចំនួននៅក្នុងប្រទេសជប៉ុនដែរ។

## តាក់ស៊ី

តាក់ស៊ីរត់នៅកន្លែងជាច្រើននៅទូទាំងប្រទេសជប៉ុន។ បើសិនអ្នកមិនចង់ឈរចាំនៅមុខស្ថានីយរថភ្លើង ឬនៅមុខចំណតឡានក្រុង យើងអាចហៅរថយន្តតាក់ស៊ីហៅតាមទូរស័ព្ទ។ បើប្រៀបធៀបទៅនឹងរថភ្លើង និងឡានក្រុងតាក់ស៊ីមានតម្លៃថ្លៃជាងបន្តិច ប៉ុន្តែយើងអាចធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀតបានយ៉ាងងាយស្រួល ខណៈពេលដែលរថភ្លើងនិងឡានក្រុងមិនអាចទៅដល់បាន។

## រថភ្លើង

ផ្លូវដែករបស់ក្រុមហ៊ុនផ្លូវដែកដែលមានឈ្មោះថា JR តភ្ជាប់ប្រទេសទាំងមូល មានផ្លូវដែកឯកជនខ្លះក៏មានប្រតិបត្តិការនៅក្នុងទីក្រុងធំៗ ដូចជា Tokyo និង Osaka ផងដែរ។ រថភ្លើងជាយានងាយស្រួលដែលអាចប្រើទោះទីជិត ឬឆ្ងាយក៏ដោយ ប៉ុន្តែមានមនុស្សជាច្រើនរស់នៅទីប្រជុំជន ហើយបានធ្វើដំណើរទៅមកយ៉ាងមមាញឹក ដូច្នេះសូមប្រុងប្រយ័ត្ន។

## ផ្លូវក្រោមដី

នៅ Tokyo និង Osaka, Nagoya, Sapporo, Fukuoka និងតំបន់ទីក្រុងដទៃទៀតដែលមានប្រជាជនច្រើនមិនមានមធ្យោបាយធ្វើដំណើរគ្រប់គ្រាន់នៅលើដងផ្លូវដូច្នេះមានខ្សែរថភ្លើងមួយទៀតដែលរត់នៅក្រោមដីហៅថា "រថភ្លើងក្រោមដី (Chika-tetsu)" ។

**សំរាប់ព័ត៌មានលំអិតអំពីផ្លូវក្រោមដី**
នៅក្នុងវេបសាយ **"Japan Visitor"**
www.japanvisitor.com/japan-travel/japan-transport/japan-subway


ថ្មី!
ខែ តុលា ឆ្នាំ២០១៧
បើកថ្នាក់ភាសាអង់គ្លេស
YouArt Academy
ទទួលស្វាគមន៍ពីកុមាររហូតដល់មនុស្សពេញវ័យ!
សម្រាប់ពង្រឹងនៅភាសាអង់គ្លេសរបស់បុគ្គលិក
ស្វាគមន៍សម្រាប់ក្រុមហ៊ុន និងជាក្រុម!
YouArt
ថ្នាក់ផ្សេងៗ.....
★ថ្នាក់ភាសាជប៉ុន
★ថ្នាក់សម្រាប់គ្រូបង្រៀន
★ថ្នាក់សិល្បៈ



កម្មវិធីពិសេស
ថ្នាក់ភាសាអង់គ្លេសសំរាប់មនុស្សពេញវ័យ
$148.5
៣ដងសម្រាប់១សប្តាហ៍ ៩០នាទី

【ម៉ោងសិក្សា】 ថ្នាក់ភាសាអង់គ្លេសសំរាប់កុមារ 8:00-11:00 (3ម៉ោង)
ថ្នាក់ភាសាអង់គ្លេសសំរាប់មនុស្សពេញវ័យ ①17:30~(90នាទី)、②19:00~(90នាទី)
【តម្លៃសិក្សា】 ថ្នាក់ភាសាអង់គ្លេសសំរាប់កុមារ ថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ $225 (10សប្តាហ៍)
ថ្នាក់ភាសាអង់គ្លេសសំរាប់មនុស្សពេញវ័យ ៣ដងសម្រាប់១សប្តាហ៍ $148.5/3ខែ (50ម៉ោង)

TEL : 070-756-377 ឈប់សំរាករៀងរាល់ថ្ងៃអាទិត្យ
【ថ្នាក់សម្រាប់មនុស្សពេញវ័យ】 #56Eo, St.95, Boeung Keng Kong 3, Chamkarmon
【ថ្នាក់សម្រាប់កុមារ】 #08, St.496, Sangkat Phsar Derm Tkov II, Khan Chamkamorn
https://www.facebook.com/YouArtAcademy

*Map of Japan*

# ផែនទីជប៉ុន




——— រថភ្លើងល្បឿនលឿន Shinkansen

( - - - - - - - - កំពុងសាងសង់ )


## សំរាប់ការផ្សព្វផ្សាយពាណិជ្ជកម្មសូមទំនាក់ទំនង

**Tel: 012-500-052, 023-726-290**
**Mail: nyonyum@cisinc.co.jp**

**nyonyum.net**

សូមធ្វើការផ្សព្វផ្សាយពាណិជ្ជកម្ម
ជាមួយទស្សនាវដ្ដីយើងខ្ញុំ

ញញឹមខ្មែរ
NyoNyum Khmer
ទស្សនាវដ្ដីយើងខ្ញុំចេញផ្សាយរៀងរាល់
ពីរខែម្ដង នៅថ្ងៃទី១០ ខែគូ

# “នាំមកនូវសុខភាពល្អទាំងអស់គ្នា” —ដើម្បីឆ្ពោះទៅពិភពមួយដែលមនុស្សទាំងឡាយអាចទទួលបាននូវសេវាសុខាភិបាលប្រកបដោយត្រឹមត្រូវ




មធ្យមភាគនៃអាយុរបស់ប្រជាជនជប៉ុន គឺវែងបំផុតនៅក្នុងពិភពលោក។

តាមរយៈប្រវត្តិសាស្ត្រ និងបទពិសោធន៍ក្នុងការបង្កើតប្រព័ន្ធសុខាភិបាលរបស់ប្រទេសជប៉ុន ទីភ្នាក់ងារ JICA បាននិងកំពុងប្រតិបត្តិការផ្តល់ជំនួយ ក្នុងគោលបំណងធ្វើឲ្យប្រជាជនមានភាពងាយស្រួលទទួលបាននូវសេវាសុខាភិបាលនៅក្នុងប្រទេសកម្ពុជា។





សម្រាប់ព័ត៌មានទាក់ទង JICA Plaza កម្ពុជា
សូមអញ្ជើញមកជាន់ទី៦, អគារ
#61-64, មហាវិថីព្រះនរោត្តម ភ្នំពេញ
ទូរស័ព្ទ ០២៣ ២១១ ៦៧៣
www.jica.go.jp/cambodia/office/about/ngodesk/about.html

❖ សម្រាប់ការពិភាក្សាសូមធ្វើការណាត់ជាមុន

## ក្រុមហ៊ុនជំនាញអំពីកម្ពុជា
## Cambodia Joho Service inc.

- សេវាបកប្រែអត្ថបទ ឬផ្ទាល់មាត់ភាសាជប៉ុន-ខ្មែរ
- ស្រាវជ្រាវព័ត៌មានផ្នែកពាណិជ្ជកម្ម និងទៅតាមតម្រូវការរបស់អតិថិជន
- រៀបចំសកម្មភាពពាណិជ្ជកម្មជាកញ្ចប់
- បោះពុម្ពទស្សនាវដ្តី “ញញឹម” និង “ញញឹមខ្មែរ”
- ផ្សព្វផ្សាយដំណឹងជ្រើសរើសបុគ្គលិក និងពាណិជ្ជកម្មផ្សេងៗតាមវិបសាយ
- ឌីហ្សាញនាមប័ណ្ណ ខិតប័ណ្ណ កាតាឡុក ប៉ូស្ទ័ ប៉ាណូពាណិជ្ជកម្ម។ល។
- លក់ផលិតផលសិប្បកម្មក្នុងស្រុក ជាពិសេសកុលាសភាជន៍ខេត្តកំពង់ឆ្នាំង។










អាស័យដ្ឋាន : ផ្ទះលេខ៤អា ផ្លូវលេខ៤៣២ សង្កាត់បឹងត្របែក ខណ្ឌចំការមន
ទូរស័ព្ទ : ០១២ ៥០០ ០៥២ / ០២៣ ៧២៦ ២៩០, cjs@cisinc.co.jp

# NEW

*Renewal in March 2018*

# ញញឹមខ្មែរ

# NyoNyum Khmer

*Japan, your neighbor*

SINCE 2014

ទស្សនាវដ្ដី "ញញឹមខ្មែរ" បានប្ដូរលក្ខណៈជាថ្មី។

ទាំងខ្លឹមសារទាំងឌីហ្សាញត្រូវប្ដូរថ្មីទាំងអស់។

កាន់តែងាយស្រួលអាន និងទាន់សម័យ។

ហើយក្នុងគោលបំណង់ចង់អោយកាន់តែស្និទ្ធស្នាលជាមួយជប៉ុន

នោះយើងបានប្រមូលប្រធានបទដែលទាក់ទងនឹងជប៉ុនជាច្រើន។

ខាងក្រោយនៃសៀវភៅនេះមានសេចក្ដីណែនាំសម្រាប់

ធ្វើដំណើរទៅប្រទេសជប៉ុន។

សូមអញ្ជើញបើកទំព័រទាំងអស់ដើម្បីទទួលអារម្មណ៍

អំពីប្រទេសជប៉ុនផង។

ញញឹមខ្មែរ NyoNyum Khmer
បោះពុម្ពផ្សាយ លេខទី២៦សម្រាប់ខែមីនា-មេសា ឆ្នាំ២០១៨

© CJSinc. 2018